**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

# ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
# និងកិច្ចការពារជនរងគ្រោះ

**រៀបរៀងដោយក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី**

**ខែឧសភា ឆ្នាំ២០០៦**

# មាតិកាអត្ថបទ

## ផ្នែកទី១ : ការយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ


១.១. សកម្មភាពនៃអំពើហិង្សាក្នុងគ្រួសារ ១

១.១.១. និយមន័យអំពើហិង្សាក្នុងគ្រួសារ ១

១.១.២. ប្រភេទនៃអំពើហិង្សាក្នុងគ្រួសារ ១

១.២. អំណាច និងការត្រួតត្រាតាមបែបហិង្សា ៣

១.៣. សមភាពនៅក្នុងការទំនាក់ទំនងគ្នា ៦

១.៤. ជំនឿ និងការពិតស្តីពីអំពើហិង្សាក្នុងគ្រួសារ ៨


## ផ្នែកទី២ : វិធានការផ្លូវច្បាប់


២.១. ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ១២

២.១.១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨ ១២

២.១.២. សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៩៣ ១២

២.១.៣. អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩ ១៣

២.១.៤. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៣

២.១.៥. បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅកម្ពុជា ក្នុងសម័យអន្តរកាល (ឆ្នាំ១៩៩២) ១៤

២.១.៦. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ១៦

២.១.៧. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ១៦

២.២. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ ២៦

២.២.១. តួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ២៦

២.២.២. តួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា ២៨

២.២.៣. តួនាទី និងភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច ២៨

២.២.៤. តួនាទី និងភារកិច្ចរបស់មន្ត្រីក្រសួងកិច្ចការនារី ៣០

២.២.៥. តួនាទី និងភារកិច្ចរបស់សហគមន៍ ៣០

២.៣. ដីកាការពារ ៣២

២.៣.១. និយមន័យ ៣២

២.៣.២. ប្រភេទ ៣២

២.៣.៣. ផលប្រយោជន៍ ៣២

២.៣.៤. អ្នកស្នើសុំ ៣៣

២.៣.៥. ការប្តឹងទាស់ ៣៣

២.៣.៦. សមត្ថកិច្ចចេញដីកាការពារ ៣៣

## ផ្នែកទី៣ : ការជួយ និងជំនួយ

៣.១. វិធីដែលមិនជួយ ៣៤

៣.២. វិធីដែលជួយ ៣៦

៣.៣. ឧបសគ្គនៅក្នុងការផ្លាស់ប្តូរទំនាក់ទំនងដែលមានការរំលោភបំពាន ៣៨

៣.៣.១. ជនរងគ្រោះខ្លាចមានការរើសអើង ៣៨

៣.៣.២. ជនរងគ្រោះភ័យខ្លាចអំពីសុវត្ថិភាពសមាជិកគ្រួសារ ៣៨

៣.៣.៣. ជនរងគ្រោះព្រួយបារម្ភអំពីជីវភាពរស់នៅ ៣៨

៣.៣.៤. ជនរងគ្រោះអាចមានជំនឿថា ខ្លួនគ្មានទីកន្លែងណាដែលត្រូវទៅនោះទេ ៣៨

៣.៣.៥. ជនរងគ្រោះនៅតែស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះជនមុខសញ្ញា ៣៩

៣.៣.៦. ជនរងគ្រោះយល់ថាអំពើហិង្សា គឺជារឿងធម្មតា ៣៩

៣.៣.៧. ជនរងគ្រោះមានជំនឿថា មិនអាចផ្លាស់ប្តូរស្ថានភាពបានទេ ៣៩

៣.៤. ការពិគ្រោះយោបល់អំពីសុវត្ថិភាពជនរងគ្រោះ ៤០

៣.៥. សកម្មភាពសហគមន៍ ៤១

៣.៦. សេវាសម្របសម្រួលផ្តល់ជំនួយក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ ៤៤

៣.៧. ការត្រួតពិនិត្យតាមដានទៅលើករណីអំពើហិង្សានៅតាមសហគមន៍ ៤៥

៣.៧.១. សារៈសំខាន់នៃការត្រួតពិនិត្យតាមដានករណីអំពើហិង្សាក្នុងគ្រួសារ ៤៥

៣.៧.២. តារាងព័ត៌មានស្តីពីអំពើហិង្សាក្នុងគ្រួសារនៅតាមសហគមន៍ប្រចាំខែ ៤៦

៣.៧.៣. តារាងព័ត៌មានស្តីពីការធ្វើអន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសាប្រចាំខែ ៤៧

# អារម្ភកថា

កម្ពុជា ជាប្រទេសមួយដែលធ្លាប់មានការអភិវឌ្ឍខឿនសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និងវប្បធម៌ធំៗថ្កើងរុងរឿង។ ប្រជាពលរដ្ឋខ្មែរ ត្រូវបានគេទទួលស្គាល់ថា ជាប្រជាពលរដ្ឋដែលមានអារ្យធម៌ឧត្តុង្គឧត្តម វប្បធម៌ ប្រពៃណី សីលធម៌ និងការអប់រំ ដ៏ថ្លៃថ្នូរ ហើយប្រកាន់ជាប់នូវព្រហ្មវិហារធម៌ទាំងបួន គឺមេត្តា ករុណា មុទិតា និងឧបេក្ខា។

ក្រោយមកអាស្រ័យដោយប្រទេសជាតិជួបប្រទះសង្គ្រាមផ្ទៃក្នុង និងសង្គ្រាមឈ្លានពាន បានធ្វើឱ្យវប្បធម៌ ប្រពៃណី សីលធម៌ និងការអប់រំធ្លាក់ចុះបន្តិចម្តងៗ ហើយធ្លាក់ចុះដល់កម្រិតសូន្យ នៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត។

ក្រោយពីប្រទេសបានទទួលសុខសន្តិភាព វប្បធម៌ ប្រពៃណី សីលធម៌ និងការអប់រំ ត្រូវបានធ្វើឱ្យប្រសើរឡើងវិញបន្តិចម្តងៗ តាមរយៈការស្តារឡើងវិញនូវគ្រប់វិស័យ និងគ្រប់លំដាប់ថ្នាក់នៃរចនាសម្ព័ន្ធរបស់រដ្ឋ និងសង្គមស៊ីវិល។ ក្នុងការគ្រប់គ្រងប្រទេស រដ្ឋបានអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវច្បាប់ជាច្រើន ជាពិសេសថ្មីៗនេះ **ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ** ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងអំឡុងខែតុលា ឆ្នាំ២០០៥។ ច្បាប់នេះមានគោលបំណង និងទិសដៅបង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ ពង្រឹងវប្បធម៌អហិង្សា និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា៤៥នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តិជាធរមាន។

ដោយយល់ឃើញពីអត្ថប្រយោជន៍ដ៏សំខាន់នៃវប្បធម៌អហិង្សា គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានបញ្ចូលប្រធានបទបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ទៅក្នុងផែនការកសាងសមត្ថភាពឆ្នាំ២០០៦របស់ខ្លួន ដើម្បីធ្វើការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានទូទាំងប្រទេស។

ឯកសារបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានរៀបចំឡើងដោយក្រសួងកិច្ចការនារី សហការជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ដោយផ្អែកតាមខ្លឹមសារច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងឯកសារច្បាប់ពាក់ព័ន្ធនានា។ ឯកសារបណ្តុះបណ្តាលនេះ ត្រូវបានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅ និងធ្វើការបណ្តុះបណ្តាលសាកល្បងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ មុននឹងដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អនុម័ត។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សង្ឃឹមថា ឯកសារបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនេះ នឹងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សូមស្វាគមន៍ និងថ្លែងអំណរសាទរ ចំពោះការផ្តល់យោបល់កែលំអនានា ពីអ្នកប្រើប្រាស់ឯកសារនេះ ។

ខែឧសភា ឆ្នាំ២០០៦

**គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

# ផ្នែកទី១

# ការយល់ដឹងអំពី

# អំពើហិង្សាក្នុងគ្រួសារ

# ផ្នែកទី១
# ការយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ

## ១.១. សកម្មភាពនៃអំពើហិង្សាក្នុងគ្រួសារ

### ១.១.១. និយមន័យអំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាក្នុងគ្រួសារ សំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត (រួមមានការប្រមាថមាក់ងាយ ការគំរាមកំហែង និងការដាក់ឱ្យនៅឯកោម្នាក់ឯង) និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលត្រូវបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាទៅលើមនុស្សផ្សេងៗទៀត ដែលកំពុងរស់នៅក្នុងគ្រួសារនោះ ។

**ន័យនៃពាក្យគ្រួសារ**

គ្រួសារមួយ មានមនុស្សដូចខាងក្រោម ÷

- ប្តី ប្រពន្ធ
- កូនក្នុងបន្ទុក (រួមមាន កូនរបស់ខ្លួនឯងផ្ទាល់ និងកូនចិញ្ចឹម)
- ជនទាំងឡាយដែលកំពុងរស់នៅក្រោមដំបូលផ្ទះតែមួយ និងក្នុងបន្ទុកគ្រួសារ ។

### ១.១.២. ប្រភេទនៃអំពើហិង្សាក្នុងគ្រួសារ

សកម្មភាពទាំងឡាយនៃអំពើហិង្សាក្នុងគ្រួសារ ត្រូវបានចែកជា៤ប្រភេទ គឺ **អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត និងអំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច។** សកម្មភាពខ្លះនៃអំពើហិង្សានេះ អាចស្ថិតក្នុងប្រភេទលើសពីមួយ ។ អំពើហិង្សាទាំងអស់ ជានិច្ចកាល បង្កឱ្យមានគ្រោះថ្នាក់ខាងផ្លូវចិត្តទៅលើជនរងគ្រោះ និងអាចបង្កគ្រោះថ្នាក់រាលដាលទៅលើសាក្សីទាំងឡាយផងដែរ ។

**ក). អំពើហិង្សាផ្លូវកាយ**

អំពើហិង្សាផ្លូវកាយមានដូចជា ការវាយដំ រុញច្រាន ទាត់ធាក់ បោចសក់ក្បាល វាយដំដោយប្រើដំបង ខាំ ក្តិច ចាប់បោក គ្រវីគ្រវាត់ ធ្វើឱ្យរងរបួសដោយប្រើឧបករណ៍ផ្សេងៗ ធ្វើឱ្យរងរបួសដោយប្រើអាវុធ ធ្វើឱ្យថប់ដង្ហើម រុញឱ្យធ្លាក់ពីលើទីខ្ពស់ ច្របាច់ក ធ្វើឱ្យរលាក ឬអុច ដាក់ថ្នាំបំពុល រំខានមិនឱ្យដេកបាន ប៉ុនប៉ងសម្លាប់ និងការសម្លាប់ ...។ល។

**ខ). អំពើហិង្សាផ្លូវភេទ**

អំពើហិង្សាផ្លូវភេទមានដូចជា ការរំលោភសេពសន្ថវៈ រំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ រំលោភបំពានផ្លូវភេទទៅលើកុមារ ឬសមាជិកក្នុងគ្រួសារ បង្ខិតបង្ខំនរណាម្នាក់ឱ្យរួមភេទជាមួយខ្លួន ឬជាមួយអ្នកដទៃ បៀតបៀនកេរ្តិ៍ខ្មាស ប្រព្រឹត្តអំពើអាស្រូវភាស និងការរំលោភបំពានផ្លូវភេទដើម្បីបន្ទាបបន្ថោកនរណាម្នាក់ ...។ល។

### គ). អំពើហិង្សាផ្លូវចិត្ត

អំពើហិង្សាផ្លូវចិត្តមានដូចជា ÷

- **អំពើហិង្សាផ្នែកពាក្យសំដី :** ការស្រែកដាក់ ការរិះគន់ឥតឈប់ឈរ និងមានរយៈពេលយូរអង្វែង ការប្រមាថមាក់ងាយនរណាម្នាក់ថា ជាមនុស្សអាក្រក់មើលណាស់ គ្មានបានការអ្វីសោះ ជាមនុស្សឆ្កួត និងឬគួរតែទៅមន្ទីរពេទ្យឆ្កួត ការបដិសេធមិនឱ្យនិយាយជាមួយនឹងអ្នកដទៃ ការធ្វើឱ្យអាម៉ាស់នៅចំពោះមុខកូនចៅ និងអ្នកដទៃ ការប្រច័ណ្ឌដោយគ្មានមូលហេតុ។
- **ការគំរាមកំហែង :** ការគំរាមកំហែងដោយប្រើអាវុធ ឬឧបករណ៍ផ្សេងៗដែលអាចប្រើប្រាស់ធ្វើជាអាវុធ ការគំរាមកំហែងយកកូនចាកចេញពីខ្លួន ការគំរាមកំហែងបណ្តេញចេញពីផ្ទះ គំរាមកំហែងធ្វើអត្តឃាត ឬធ្វើឃាត គំរាមកំហែងចាប់ពង្រត់កូន ឬរំលោភបំពានទៅលើកូន គំរាមកំហែងធ្វើកាយវិកលកម្ម (ការកាត់ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់សារពាង្គកាយ) គំរាមកំហែងវាយដំ គំរាមកំហែងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ គំរាមកំហែងរារាំងមិនឱ្យទៅធ្វើការងារ គំរាមកំហែងលក់នាង ឬគាត់ (អំពើជួញដូរមនុស្ស) និងការប្រកាសថាខ្លួនមានសិទ្ធិធ្វើដូច្នេះបានពីព្រោះខ្លួនបានចំណាយប្រាក់សម្រាប់ចំណងដៃក្នុងពេលរៀបអាពាហ៍ពិពាហ៍ ជាដើម . . .។
- **ការដកហូតសេរីភាព (ការដាក់ឱ្យនៅឯកោម្នាក់ឯង) :** ការបដិសេធមិនឱ្យជួបជាមួយនឹងបងប្អូនគ្រួសារ និងមិត្តភក្តិរបស់នាងឬគាត់ ការចាក់សោបង្ខាំងទុកក្នុងបន្ទប់ ការរារាំងមិនឱ្យចាកចេញពីបរិវេណផ្ទះសម្បែង ឬទៅធ្វើការងារ ឬទៅរៀនសូត្រ ការដើរតាមទៅគ្រប់ទីកន្លែងទាំងអស់ដែលនាងឬគាត់ធ្វើដំណើរទៅ ការត្រួតត្រាទៅលើទិដ្ឋភាពទាំងអស់នៃការធ្វើសេចក្តីសម្រេចចិត្តរបស់គ្រួសារ . . .។

### ឃ). អំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច

អំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច មានដូចជា ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមានតម្លៃ (ឧទាហរណ៍ : ការបោកបំបែកចាន ឆ្នាំង កែវទឹក ការដុតផ្ទះសម្បែង ...) ការបដិសេធមិនឱ្យលុយកាក់ ការឱ្យនរណាម្នាក់តាមសុំប្រាក់ខ្លួនជាប់រហូត ការបង្ខិតបង្ខំឱ្យនរណាម្នាក់ចុះហត្ថលេខាដើម្បីខ្ចីប្រាក់ ឬការដណ្តើមយកទ្រព្យសម្បត្តិ។

ជាទូទៅ អំពើហិង្សាផ្លូវកាយ គឺជាប្រភេទអំពើហិង្សាមួយដែលអាចមើលឃើញដោយងាយបំផុត ហើយអាចមានផលវិបាកយ៉ាងធ្ងន់ធ្ងរដែលបណ្តាលឱ្យមានការរងរបួស និងការបាត់បង់ជីវិត។ ទន្ទឹមនឹងនោះ អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្លូវចិត្ត ដែលមានផលប៉ះពាល់ដល់សុខុមាលភាពផ្លូវចិត្តរបស់មនុស្សម្នាក់ ជួនកាលផលប៉ះពាល់នោះ អាចបណ្តាលឱ្យរងគ្រោះថ្នាក់អស់មួយជីវិត ឬមានអំពើអត្តឃាត (ការសម្លាប់ខ្លួនឯង) ឬអំពើមនុស្សឃាត (ការសម្លាប់អ្នករំលោភបំពាន)។

## ១.២. អំណាច និងការគ្រួតត្រាតាមបែបហិង្សា

**អំណាច និងការគ្រួតត្រាតាមបែបហិង្សា** គឺបរិយាយអំពី ÷

- អាកប្បកិរិយា និងឥរិយាបថរបស់ជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ
- មូលហេតុដែលនៅពីក្រោយអាកប្បកិរិយារបស់ជនមុខសញ្ញា
- វិធីសាស្ត្រផ្សេងៗដែលជនមុខសញ្ញាបានប្រើប្រាស់ ដើម្បីបង្ខំឱ្យជនរងគ្រោះត្រូវតែធ្វើតាមបំណងប្រាថ្នារបស់ខ្លួនដូចជា ការបំភិតបំភ័យ ការរំលោភបំពានផ្លូវចិត្ត ការដាក់ឱ្យនៅឯកោតែម្នាក់ឯង ការបដិសេធ និងការស្តីបន្ទោស ការរំលោភបំពានផ្នែកជីវភាពសេដ្ឋកិច្ច ការបំពានសមភាពយេនឌ័រ និងការបង្ខិតបង្ខំ គំរាមកំហែង ។

សកម្មភាពហិង្សាទាំងអស់របស់ជនមុខសញ្ញា ធ្វើឡើងក្នុងគោលបំណងដើម្បីរក្សាអំណាច និងការគ្រួតត្រាតាមបែបហិង្សារបស់ខ្លួន ទៅលើជនរងគ្រោះ និងទុកជនរងគ្រោះឱ្យស្ថិតនៅក្នុងស្ថានភាពភ័យខ្លាចជាប់ជាប្រចាំ ។

### សេចក្តីពន្យល់អំពីរបៀបមើលកង់ចក្រអំណាច និងការគ្រួតត្រាតាមបែបហិង្សា

កង់ចក្រនេះ មានរាងជារង្វង់ ដែលមាន៣ជាន់ ÷

☞ **រង្វង់ទី១** ( រង្វង់ខាងក្រៅ ) មានអក្សរនៅព័ទ្ធជុំវិញ គឺ ÷

- **ខាងលើ និងខាងក្រោម** មានអក្សរធំៗថា **អំពើហិង្សាផ្លូវកាយ ផ្លូវភេទ**
- **ខាងឆ្វេង** មានអក្សរតូចៗ ដូចជា ដាល់ ទះកំផ្លៀង ច្របាច់ក បោចសក់ ស្តោះទឹកមាត់ដាក់ ខាំ វាយដំ ធ្វើឱ្យរលាក គ្រវីគ្រវាត់ គំរាមកំហែង ឬប្រើប្រាស់អាវុធ
- **ខាងស្តាំ** មានអក្សរតូចៗដូចជា ចាប់រំលោភ ទាមទារការរួមភេទ បង្ខំរួមភេទដែលគ្មានសុវត្ថិភាព ប្រច័ណ្ឌថាដៃគូរបស់ខ្លួនរួមភេទជាមួយអ្នកផ្សេង ។

ផ្នែករង្វង់ខាងក្រៅនេះ ជាទិដ្ឋភាពរួមនៃអំពើហិង្សានៅក្នុងគ្រួសារ ដែលអាចកើតឡើង ហើយងាយមើលឃើញជាទីបំផុត ។

☞ **រង្វង់ទី២** ចែកចេញជា៨ចំណែករាងដូចកាំរទេះ ហើយចំណែកទាំង៨នោះ មានលើកឡើងនូវចំណុចខ្លះៗ មួយចំនួនដែលជនមុខសញ្ញាប្រព្រឹត្ត ÷

- ការបំភិតបំភ័យ
- ការរំលោភបំពានផ្លូវចិត្ត
- ការដាក់ឱ្យនៅឯកោតែម្នាក់ឯង
- ការបដិសេធ និងការស្តីបន្ទោស

- ការប្រើប្រាស់កូន
- ការរំលោភបំពានផ្នែកជីវភាពសេដ្ឋកិច្ច
- វិសមភាពយេនឌ័រ
- ការបង្ខិតបង្ខំ និងការគំរាមកំហែង ។

ផ្នែកទី២នេះ រៀបរាប់អំពីសកម្មភាពអំពើហិង្សាដែលមិនងាយមើលឃើញ ។

☞ **រង្វង់ខាងក្នុង ឬស្នូល** មានអក្សរថា **អំណាច និងការត្រួតត្រាតាមបែបហិង្សា** គឺនិយាយអំពីអំណាច និងការត្រួតត្រាតាមបែបហិង្សារបស់ជនមុខសញ្ញា ប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះក្នុងគ្រួសារ ។

☞ **អត្ថន័យ :**

- ប្រសិនបើសកម្មភាពដូចមានក្នុងរង្វង់ទី២នៅតែបន្ត នោះរង្វង់ខាងក្នុងដែលជាស្នូល ក៏កាន់តែរីកធំឡើងៗ ហើយរង្វង់ទី១ (រង្វង់ខាងក្រៅ) ក៏កាន់តែរីកធំឡើងថែមទៀតដែរ មានន័យថា ប្រសិនបើជនមុខសញ្ញានៅតែបន្តប្រព្រឹត្តសកម្មភាពហិង្សា ដូចមានបរិយាយនៅក្នុងផ្នែកខ្លះនៃចំណែកទាំង៨នៃរង្វង់ទី២នេះ នោះអំណាច និងការត្រួតត្រាតាមបែបហិង្សារបស់ជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ នឹងកាន់តែកើនឡើង ហើយសកម្មភាពនៃអំពើហិង្សានៅក្នុងគ្រួសារនៅស្រទាប់ខាងក្រៅក៏កាន់តែស្តែងចេញខ្លាំងឡើងៗថែមទៀត ។
- ផ្ទុយមកវិញ ប្រសិនបើសមាជិកគ្រួសារនីមួយៗ ប្រកាន់យកឥរិយាបថអហិង្សា មិនប្រព្រឹត្តសកម្មភាពដូចមានបរិយាយនៅក្នុងផ្នែកខ្លះនៃចំណែកទាំង៨នៃរង្វង់ទី២នេះ នោះអំណាច និងការត្រួតត្រាតាមបែបហិង្សារបស់ជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ នឹងកាន់តែថយចុះ ឬគ្មាន ហើយសកម្មភាពនៃអំពើហិង្សានៅក្នុងគ្រួសារនៅស្រទាប់ខាងក្រៅ កាន់តែរួមតូចថែមទៀត មានន័យថា អំពើហិង្សាក្នុងគ្រួសារ នឹងមិនកើតមានទៀតឡើយ ។

## គង់ចក្រអំណាច និងការត្រួតត្រាតាមបែបហិង្សា



## ១.៣. សមភាពនៅក្នុងការទំនាក់ទំនងគ្នា

**សមភាពនៅក្នុងទំនាក់ទំនងគ្នា** គឺចង់បង្ហាញដល់ជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារអំពីជម្រើសផ្សេងៗនៅក្នុងការដោះស្រាយទំនាស់នានាដោយសន្តិវិធី ដើម្បីស្តារឡើងវិញនូវវប្បធម៌អហិង្សានៅក្នុងគ្រួសារ និងសង្គម ។

### សេចក្តីពន្យល់អំពីរបៀបមើលកង់ចក្រសមភាព

កង់ចក្រនេះ មានរាងជារង្វង់ ដែលមាន៣ជាន់ គឺ ÷

☞ **រង្វង់ទី១** ( រង្វង់ខាងក្រៅ) : មានអក្សរធំៗនៅខាងលើ និងខាងក្រោម សរសេរថា **ភាពអហិង្សា។** ផ្នែករង្វង់ខាងក្រៅនេះ ជាទិដ្ឋភាពរួមនៃភាពអហិង្សានៅក្នុងគ្រួសារ នៅពេលដែលសកម្មភាពហិង្សា ត្រូវបានលុបបំបាត់ ។

☞ **រង្វង់ទី២** ចែកចេញជា៨ចំណែករាងដូចកាំរទេះ ហើយចំណែកទាំង៨នោះ មានលើកឡើងនូវសកម្មភាពល្អៗ មួយចំនួន ដែលជនមុខសញ្ញាត្រូវមាន ÷

- អាកប្បកិរិយាមិនគំរាមកំហែង
- ការគោរពគ្នា
- ជំនឿទុកចិត្ត និងការគាំទ្រ
- ចិត្តស្មោះត្រង់ និងគណនេយ្យភាព
- ការទទួលខុសត្រូវ ក្នុងនាមជាឪពុក ម្តាយ
- ភាពជាដៃគូនៅក្នុងជីវភាពសេដ្ឋកិច្ច
- ការចែករំលែកការទទួលខុសត្រូវ
- ការចរចា និងភាពយុត្តិធម៌ ។

☞ **រង្វង់ខាងក្នុង ឬស្នូល** មានអក្សរថា **សមភាព** គឺនិយាយអំពីអំណាច និងការត្រួតត្រារបស់ជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ត្រូវបានកាត់បន្ថយ និងមានតុល្យភាពជាមួយនឹងជនរងគ្រោះ ។

☞ **អត្ថន័យ :**

ប្រសិនបើសកម្មភាពដូចមានក្នុងរង្វង់ទី២ត្រូវបានអនុវត្ត នោះរង្វង់ខាងក្នុងដែលជាស្នូល ក៏កាន់តែរីកធំឡើងៗ ហើយរង្វង់ទី១ ( រង្វង់ខាងក្រៅ) ក៏កាន់តែរីកធំថែមទៀតដែរ មានន័យថា ប្រសិនបើជនមុខសញ្ញាប្រព្រឹត្តសកម្មភាពដូចមានបរិយាយនៅក្នុងចំណែកទាំង៨នៃរង្វង់ទី២នេះ នោះសមភាពនៃសិទ្ធិរបស់ជនមុខសញ្ញា និងជនរងគ្រោះ កាន់តែត្រូវបានលើកកម្ពស់ ហើយសកម្មភាពអហិង្សានៅក្នុងគ្រួសារ ( នៅស្រទាប់ខាងក្រៅ) ក៏ស្តែងចេញកាន់តែខ្លាំងឡើងៗ ដែលនាំឱ្យមានភាពសុខដុមរមនាក្នុងគ្រួសារ និងសង្គមជាតិទាំងមូល ។

## កង់ចក្រសមភាព


ភាពអហិង្សា
សមភាព
១. មិនប្រើអាកប្បកិរិយាគំរាមកំហែង
ពិភាក្សាគ្នា និងធ្វើសកម្មភាពដែលនាំឱ្យ
ភាគីម្ខាងទៀត មានអារម្មណ៍ប្រកបដោយ
សុវត្ថិភាពនៅក្នុងការសំដែងមតិ
យោបល់ និងធ្វើការងារ
ទាំងឡាយតាមសម្រួល ។
២. ការគោរពគ្នា
- យោគយល់គ្នា
- ស្តាប់មតិយោបល់គ្នា
- ចាត់ទុកគេស្មើនឹងខ្លួនអ្នកដែរ
- ឱ្យតម្លៃលើមតិយោបល់គ្នាទៅវិញទៅមក ។
៣. ជំនឿទុកចិត្ត និងការគាំទ្រ
- គាំទ្រគោលបំណង
- គោរពសិទ្ធិក្នុងការគិតគូរពិចារណា
- គោរពសិទ្ធិ និងផ្តល់ឱកាសឱ្យភាគី
ម្ខាងទៀត បញ្ចេញទស្សនៈ
របស់ខ្លួនផ្ទាល់ ។
៤. ចិត្តស្មោះត្រង់
និងគណនេយ្យភាព
ទទួលខុសត្រូវចំពោះ
អាកប្បកិរិយារបស់ខ្លួន ។ ទទួល
ស្គាល់អំពីការប្រើប្រាស់អំពើហិង្សា
កាលពីអតីតកាល ។ សារភាពថាសកម្មភាព
ទាំងនោះពិតជាមានការខុសឆ្គងមែន ។
ជជែកគ្នាដោយចំហ និងដោយ
សុចរិត ។
៥. ធ្វើជាឪពុកម្តាយ
ដែលមានការទទួលខុសត្រូវ
ចែករំលែកការទទួលខុសត្រូវ
ក្នុងនាមជាឪពុកម្តាយ ។ ធ្វើជាគំរូល្អ
និងអហិង្សា ចំពោះសមាជិកគ្រួសារ ។
៦. ភាពជាដៃគូនៅក្នុងជីវភាពសេដ្ឋកិច្ច
ធ្វើសេចក្តីសម្រេចចិត្តផ្នែកលុយកាក់ទាំងអស់គ្នា ។
ដឹងច្បាស់ថា ដៃគូទាំងពីរនាក់ទទួលបានផល
ប្រយោជន៍ពីការចាត់ចែងបញ្ហាហិរញ្ញវត្ថុ
ទាំងឡាយ ។ មានឱកាសស្មើគ្នាក្នុងការរក
និងប្រើប្រាស់ប្រាក់ចំណូល ។
៧. ការចែករំលែក
ការទទួលខុសត្រូវ
មានការឯកភាព និងយល់ព្រម
ទាំងអស់គ្នាចំពោះ :
- ការបែងចែកការងារដោយយុត្តិធម៌
- ការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗលើបញ្ហាគ្រួសារ ។
- កំណត់អំពីការទទួលខុសត្រូវ និងតួនាទីអ្វីខ្លះ
ដែលខ្លួនគួរមាននៅក្នុងគ្រួសារ ។
៨. ការចរចាគ្នា និងភាពយុត្តិធម៌
ព្យាយាមរកដំណោះស្រាយដែលអាច
ទទួលយកបានទាំងអស់គ្នា ចំពោះបញ្ហា
ផ្សេងៗដែលកើតមានក្នុងគ្រួសារ ។
ទទួលយកការផ្លាស់ប្តូរទាំងឡាយ ។
មានសុឆន្ទៈដើម្បីសម្រប
សម្រួលគ្នាក្នុងរង្វង់គ្រួសារ ។
ភាពអហិង្សា

## ១.៤. ជំនឿ និងការពិតស្តីពីអំពើហិង្សាក្នុងគ្រួសារ

មនុស្សគ្រប់រូបតែងមានទស្សនៈ ការគិតគូរពិចារណា និងការយល់ឃើញផ្សេងៗគ្នា អាស្រ័យលើបរិស្ថាននៃការរស់នៅ បរិយាកាសសង្គម ប្រព័ន្ធអប់រំ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងកត្តាពាក់ព័ន្ធផ្សេងៗទៀត។ ការយល់ឃើញរបស់បុគ្គលនីមួយៗចំពោះហេតុការណ៍ណាមួយ មិនមែនសុទ្ធតែត្រឹមត្រូវទាំងអស់ដូចៗគ្នាទេ ហើយក៏មិនមែនមានន័យថា សុទ្ធតែមិនត្រឹមត្រូវទាំងអស់គ្នានោះដែរ។ ប្រការសំខាន់នៅត្រង់ថា តើអ្នកវិភាគហេតុការណ៍បានវិភាគគ្រប់ជ្រុងជ្រោយដែរឬទេ? ឧទាហរណ៍ : តើមានរឿងអ្វីកើតឡើង? ដោយមូលហេតុអ្វី? តើព័ត៌មានស្តីពីហេតុការណ៍នោះ ពិតជាត្រឹមត្រូវអាចទទួលយកបានដែរឬទេ? តើត្រូវដោះស្រាយបែបណា? តើដំណោះស្រាយនោះមានប្រសិទ្ធភាពដែរឬទេ? . . .។ល។

យ៉ាងណាមិញ ការរស់នៅក្នុងសហគមន៍ អាចមានប្រជាពលរដ្ឋខ្លះធ្លាប់បានជួបប្រទះ ឬដឹងឮអំពីអំពើហិង្សានៅក្នុងគ្រួសារដែលកើតមានក្នុងសហគមន៍របស់គាត់ ឬខាងក្រៅសហគមន៍។ អំពើហិង្សានោះអាចកើតមានម្តងម្កាល ឬញឹកញាប់ ហើយខណៈនោះ ប្រាកដជាមានការសន្និដ្ឋាន ឬការយល់ឃើញផ្សេងៗគ្នាអំពីអំពើហិង្សាពីសំណាក់មតិមួយចំនួនជាក់ជាមិនខាន។

ខាងក្រោមនេះ ជាទស្សនៈ ឬការយល់ឃើញដោយភាន់ច្រឡំអំពីអំពើហិង្សាក្នុងគ្រួសារ ដែលដក់ជាប់ក្នុងអារម្មណ៍របស់បុគ្គលមួយចំនួន និងការឆ្លុះបញ្ចាំងអំពីការពិតស្តីពីអំពើហិង្សាក្នុងគ្រួសារ ៖

☞ **ទស្សនៈទី១ :** អ្នកខ្លះជឿថា "ការឈ្លោះប្រកែកគ្នា និងការវាយដំគ្នានៅក្នុងរង្វង់គ្រួសារ គឺជាលក្ខណៈនៃការរស់នៅរបស់ក្រុមមនុស្សដែលគ្មានការអប់រំ និងក្រុមមនុស្សដែលមានជីវភាពក្រីក្រ"។

☞ **ការពិតទី១ :**

- អំពើហិង្សាក្នុងគ្រួសារ កើតមានឡើងមិនមានលក្ខណៈខុសប្លែកគ្នាដោយសារកត្តាខាងសេដ្ឋកិច្ច ជាតិសាសន៍ និងវណ្ណៈនោះទេ។ អំពើហិង្សាក្នុងគ្រួសារ អាចកើតមានឡើងនៅគ្រប់ទីកន្លែងទាំងអស់ និងក្នុងគ្រួសារគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម។
- នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋក្រីក្រ ច្រើនរស់នៅក្នុងផ្ទះតូចៗ មិនមានបន្ទប់ឬជញ្ជាំងបិទបាំងជិត និងមាំទាំនោះឡើយ។ ហេតុដូច្នេះ ពេលដែលមានការឈ្លោះប្រកែកគ្នានៅក្នុងចំណោមសមាជិកគ្រួសារ វាមានលក្ខណៈងាយស្រួលសម្រាប់អ្នកជិតខាងដឹងឮ ឬកត់សម្គាល់ ហើយបញ្ហានេះ អាចនឹងបណ្តាលឱ្យមានជំនឿភាន់ច្រឡំថា មានតែអ្នកក្រទេ ដែលឈ្លោះប្រកែកគ្នាក្នុងគ្រួសារ។
- តែទោះជាយ៉ាងណាក៏ដោយ អ្នកមានប្រាក់ អ្នកមានអំណាច ឬអ្នកមានការសិក្សាអប់រំខ្ពស់ គេមានលទ្ធភាពរស់នៅក្នុងផ្ទះធំៗ មានរបងហ៊ុំព័ទ្ធបិទបាំងមាំទាំ មិនអាចឱ្យអ្នកជិតខាង មើលឃើញ ស្តាប់ឮការឈ្លោះប្រកែករបស់ពួកគេក្នុងគ្រួសារដោយងាយៗឡើយ ឬអាចមានការខ្មាស់អៀន នៅក្នុងការរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសាររបស់ពួកគេ (ដោយគិតថា ពួកគេនឹងត្រូវបាក់មុខមាត់នៅក្នុងសង្គម បើសាធារណជនដឹងថា គ្រួសារគេមានអំពើហិង្សានោះ)។

☞ **ទស្សនៈទី២ :** អ្នកខ្លះជឿថា "អំពើហិង្សាក្នុងគ្រួសារ គឺជារឿងផ្ទៃក្នុងមួយរបស់គ្រួសារ មិនមែនជាបញ្ហារបស់សង្គមទេ"។

☞ **ការពិតទី២ :**

- អំពើហិង្សាក្នុងគ្រួសារ បាននាំមកនូវការខូចប្រយោជន៍ដ៏ច្រើនដល់គ្រួសារ និងសង្គមជាតិ។ ឧទាហរណ៍ : ការព្យាបាលជម្ងឺ ការខូចខាតទ្រព្យសម្បត្តិ ការបាត់បង់សមត្ថភាពពលកម្ម និងការរកប្រាក់ចំណូល កុមារមិនអាចទៅសាលារៀនបាន និងបញ្ហាផ្សេងៗជាច្រើនទៀត។ ការខូចប្រយោជន៍ដល់សង្គម ដូចជា បាត់បង់ធនធានមនុស្ស ខាតបង់ពេលវេលា ខាតបង់ថវិកាជាតិ សីលធម៌ វប្បធម៌ ប្រពៃណីដ៏ល្អរបស់សង្គមខ្មែរធ្លាក់ចុះ ប្រទេសមិនមានការអភិវឌ្ឍ។
- ច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលដាក់ឱ្យអនុវត្តនៅកម្ពុជា មិនបានទាត់ចោលសមាជិកគ្រួសារពីការផ្តន្ទាទោស ក្នុងករណីដែលពួកគេប្រព្រឹត្តអំពើហិង្សានោះឡើយ។ ហេតុដូច្នេះ អាជ្ញាធរមូលដ្ឋាន និងតុលាការ ត្រូវមានកាតព្វកិច្ចធ្វើអន្តរាគមន៍ក្នុងករណីកើតមានអំពើហិង្សា។

**ច្បាប់ព្រហ្មទណ្ឌ មាត្រា៤១ អំពើបង្ករបួសដោយចេតនា បានចែងថា :**

ជនណាវាយតប់បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្ន ក្នុងរយៈពេលលើសពី៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុក ពី១ឆ្នាំទៅ៥ឆ្នាំ។

- បើពិការភាពបណ្តោះអាសន្ននោះតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះ ពី៦ខែ ដល់២ឆ្នាំ។
- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាទោសដាក់គុកពី២ខែ ទៅ១ឆ្នាំ។
- បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កម្រិតទោសត្រូវទ្វេមួយជាពីរ។

**ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មាត្រា១ ចែងថា :**

ច្បាប់នេះមានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គមនៅព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះ មានទិសដៅបង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តិជាធរមាន។

☞ **ទស្សនៈទី៣ :** អ្នកខ្លះជឿថា "បុរសខ្លះប្រើអំពើហិង្សាទៅលើប្រពន្ធរបស់គាត់ ដោយសារប្រពន្ធព្យាយាមផ្តល់ហេតុផលចំពោះរឿងអ្វីមួយដល់គាត់"។

☞ **ការពិតទី៣ :**

- ជនមុខសញ្ញា ជានិច្ចកាលនឹងព្យាយាមរកលេសដោះសាចំពោះអំពើរបស់ខ្លួន បើទោះបីជាជនរងគ្រោះបានធ្វើអ្វីមួយ ឬមិនបានធ្វើអ្វីមួយក៏ដោយ។

- ជនមុខសញ្ញាម្នាក់ ជាធម្មតានៅពេលដែលគេរំលោភបំពានទៅលើជនរងគ្រោះ គឺនៅពេលដែលគេដឹងថាជនរងគ្រោះនៅតែម្នាក់ឯង មិនមាននរណាម្នាក់អាចធ្វើជាសាក្សីឡើយ (ប្រសិនបើមានមនុស្សធ្វើជាសាក្សីនោះ ក៏ច្រើនតែជាកុមារតែប៉ុណ្ណោះ) ។ ជនមុខសញ្ញាមានការត្រួតត្រាទៅលើស្ថានការណ៍នោះថាតើគេត្រូវវាយដំជនរងគ្រោះញឹកញាប់ និងធ្ងន់ធ្ងរយ៉ាងដូចម្តេច ។
- មានទស្សនៈខ្លះយល់ច្រឡំថា បុរស គឺជាមេគ្រួសារ ហើយក្នុងការដឹកនាំគ្រួសារ មេគ្រួសារមានសិទ្ធិត្រួតត្រា និងប្រើហិង្សាលើសមាជិកគ្រួសាររបស់ខ្លួន។ ទស្សនៈនេះ បានប្រឆាំងនឹងអនុសញ្ញាអន្តរជាតិទាំងអស់ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខារួចហើយ ក៏ដូចជាបានប្រឆាំងនឹងរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះផងដែរ ។

☞ **ទស្សនៈទី៤ :** អ្នកខ្លះជឿថា "បុរសទាំងឡាយប្រើអំពើហិង្សា នៅពេលដែលពួកគេស្រវឹងស្រា ដោយមិនបានដឹងថាខ្លួនកំពុងតែធ្វើអ្វីនោះទេ" ។

☞ **ការពិតទី៤ :**

- សុរាមិនមែនជាបុព្វហេតុតែមួយគត់នៃការប្រព្រឹត្តអំពើហិង្សានោះឡើយ ហើយមតិដែលយល់ថា ការសេពសុរាបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ គឺជាការភាន់ច្រឡំ ឬជាលេសដោះសាររបស់គេតែប៉ុណ្ណោះ ។ បុរសខ្លះមានភាពហិង្សានៅពេលដែលពួកគេស្រវឹងស្រា តែបុរសខ្លះទៀត នៅពេលដែលពួកគេមិនស្រវឹងស្រាក៏មានភាពហិង្សាដែរ ។
- ចូរកត់សម្គាល់ថា ការផឹកស្រាមិនមែនជារឿងខុសច្បាប់ទេ ប៉ុន្តែការប្រព្រឹត្តអំពើហិង្សានៅពេលស្រវឹងស្រា គឺជាការខុសច្បាប់ដូចការប្រព្រឹត្តអំពើហិង្សាក្នុងគ្រាមិនស្រវឹងស្រាដែរ ។

<u>**កំណត់សម្គាល់**</u> : អ្នកខ្លះតែងតែផឹកស្រាដើម្បីបំភ្លេចបញ្ហាទាំងឡាយ ឬបញ្ចេញនូវភាពតានតឹងក្នុងចិត្តរបស់ខ្លួន។ តែទោះជាយ៉ាងណាក៏ដោយ ការផឹកស្រាក្នុងបរិមាណដ៏ច្រើនជាទៀងទាត់ អាចបណ្តាលឱ្យញៀនហើយថែមទាំងមិនអាចដោះស្រាយបញ្ហាបានទៀតផង។ ជាងនេះទៀត វាអាចនឹងបង្កើតឱ្យមានបញ្ហាកាន់តែច្រើនថែមទៀតតែប៉ុណ្ណោះ ។

☞ **ទស្សនៈទី៥ :** អ្នកខ្លះជឿថា "អំពើហិង្សានៅក្នុងគ្រួសារមួយ គឺមិនមែនជារឿងធ្ងន់ធ្ងរណាស់ណាទេ ប្តីប្រពន្ធគ្រប់ៗរូប ជួនកាលមានការឈ្លោះប្រកែកគ្នាតែអ៊ីចឹងឯង" ។

☞ **ការពិតទី៥ :**

- ពាក្យនេះតែងតែត្រូវបានប្រើប្រាស់ជាទៀងទាត់ ដោយជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សា ដែលចង់មានលេសដោះសាចំពោះអាកប្បកិរិយាដ៏អាក្រក់របស់ខ្លួន ដោយគ្រាន់តែនិយាយថា វាគឺជាការឈ្លោះប្រកែកគ្នាធម្មតាទេ។ អ្នកខ្លះតែងតែប្រើពាក្យថា ការឈ្លោះប្រកែកគ្នានេះ សម្រាប់ស្ថានការណ៍ដែលពួកគេមានការខ្វែងគំនិត និងមតិយោបល់គ្នា ។

- ជាធម្មតា ក្នុងការរស់នៅ និងការទំនាក់ទំនងគ្នា តែងតែមានការខ្វែងគំនិត និងមតិយោបល់គ្នា ប៉ុន្តែបើការខ្វែងគំនិតគ្នានោះ មិននាំឱ្យមានអំពើហិង្សា នោះជាការប្រសើរបំផុត។
- អំពើហិង្សាមិនមែនជាការខ្វែងគំនិត និងមតិយោបល់គ្នានោះឡើយ ពោលគឺវាជាការប្រើប្រាស់អំណាចផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងការគំរាមកំហែង ដើម្បីគ្រប់គ្រង និងត្រួតត្រាដោយហិង្សាទៅលើការគិតគូរការបញ្ចេញយោបល់ទស្សនៈ និងអារម្មណ៍របស់ជនរងគ្រោះ។ ជួនកាលមនុស្សទាំងឡាយនឹងមានភាពហិង្សា នៅក្នុងពេលឈ្លោះប្រកែកគ្នា ពីព្រោះពួកគេមានអារម្មណ៍ថា ខ្លួនកំពុងតែស្ថិតនៅក្នុងស្ថានភាពចាញ់គេ នៅក្នុងការឈ្លោះប្រកែកគ្នានោះ។
- នៅក្នុងទំនាក់ទំនងមួយដែលមានអំពើហិង្សា មិនមានការពិភាក្សាគ្នាអំពីការខ្វែងគំនិត មតិយោបល់ដោយស្មើភាពនោះទេ ជនរងគ្រោះ (ដែលភាគច្រើនជាស្ត្រី និងកុមារនោះ) តែងតែយល់ព្រមដោយការភ័យខ្លាច។

| |
|---|
| ☞ **ទស្សនៈទី៦ :** អ្នកខ្លះជឿថា "កុមារត្រូវការមានឪពុក ម្តាយ ដូច្នេះឪពុក ម្តាយមិនគួរលែងលះគ្នានោះទេ"។ |

☞ **ការពិតទី៦ :**

- កុមារដែលរស់នៅក្នុងគ្រួសារដែលមានការរំលោភបំពាន ទទួលរងការឈឺចាប់ខ្លាំង មិនដូចកុមារដែលរស់នៅក្នុងគ្រួសារដែលគ្មានអំពើហិង្សានោះឡើយ។ កុមារទាំងនោះ ទទួលរងការឈឺចាប់ខាងផ្លូវចិត្តផ្លូវកាយ ទទួលរងការវាយដំ ការគំរាមកំហែង និងទទួលរងការរំខាននៅក្នុងការដេក ការរៀនសូត្រ និងភាពសុខដុមរបស់ពួកគេ។
- កុមារដែលទទួលរងការរំលោភបំពាន អាចក្លាយខ្លួនទៅជាអ្នករំលោភបំពានវិញ នៅពេលដែលពួកគេធំឡើង។ ដូច្នេះ បើស្ថានភាពរំលោភបំពានធ្ងន់ធ្ងរ ការសម្រេចចិត្តដើម្បីចាកចេញ ឬលែងលះពីអ្នកប្រើអំពើហិង្សា ទំនងជានឹងមានផលប្រយោជន៍ចំពោះកូនក៏ថាបាន ព្រោះចៀសវាងការធ្វើឱ្យពួកគេមានគ្រោះថ្នាក់ទៅថ្ងៃមុខ។
- តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសកម្ពុជា វាមានការលំបាកខ្លាំងណាស់នៅក្នុងការចាកចេញពីគ្រួសារ។ ជាការពិត ស្ត្រីខ្លះដែលពឹងពាក់ទាំងស្រុងលើសេដ្ឋកិច្ចរបស់ប្តី អាចមានការលំបាកក្នុងការសម្រេចចិត្តដើម្បីចាកចេញឬលែងលះ ដោយសារអាចមានបញ្ហាប្រឈមនឹងជីវភាពរស់នៅ នៅពេលអនាគតក្រោយការលែងលះ។

# ផ្នែកទី២
# វិធានការផ្លូវច្បាប់

# ផ្នែកទី២
# វិធានការផ្លូវច្បាប់

## ២.១. ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា

### ២.១.១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨

- **មាត្រា៣ :** បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។
- **មាត្រា៥ :** គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ ។

### ២.១.២. សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី របស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៩៣

- អំពើហិង្សាលើស្ត្រីមានន័យថា ជាអំពើហិង្សាណាមួយដែលបណ្តាលឱ្យមាន ឬអាចនឹងបណ្តាលឱ្យមាន គ្រោះថ្នាក់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដល់ស្ត្រី រាប់ទាំងការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត ទោះជាកើតមាននៅក្នុងជីវភាពរស់នៅជាសាធារណៈ ឬជាឯកជនក៏ដោយ ។
- សេចក្តីប្រកាសនេះកំណត់ថា អំពើហិង្សាក្នុងគ្រួសារ គឺជាអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតឡើងនៅក្នុងគ្រួសារ រាប់ទាំងការវាយដំ ការរំលោភបំពានផ្លូវភេទទៅលើកុមារនៅក្នុងគ្រួសារ អំពើហិង្សាដែលទាក់ទងជាមួយនឹងបញ្ហាបង់ប្រាក់ចំណងដៃអាពាហ៍ពិពាហ៍ បញ្ហារំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ បញ្ហាធ្វើកាយវិកលកម្មលើកេរ្តិ៍ភេទស្ត្រី និងបញ្ហាអនុវត្តតាមប្រពៃណីផ្សេងៗទៀតដែលមានគ្រោះថ្នាក់ដល់ស្ត្រី និងអំពើហិង្សាមិនមែនលក្ខណៈប្តីប្រពន្ធដែលទាក់ទងជាមួយនឹងការកេងប្រវ័ញ្ច ។

**រដ្ឋាភិបាលមានកាតព្វកិច្ច :**

- បញ្ចៀសការប្រព្រឹត្តិអំពើហិង្សាលើស្ត្រី ។
- ទប់ស្កាត់ ស៊ើបអង្កេត និងដាក់ទណ្ឌកម្មដល់ជនប្រព្រឹត្តអំពើហិង្សាលើស្ត្រី បើទោះបីជាអំពើទាំងនោះត្រូវបានប្រព្រឹត្តនៅក្នុងគ្រួសារ ឬនៅក្នុងសង្គមក៏ដោយ ។
- ផ្តល់សិទ្ធិទទួលបាននូវដំណោះស្រាយតាមផ្លូវច្បាប់ និងជំនួយពីផ្នែកជំនាញឯកទេសសមស្រប និងមានប្រសិទ្ធភាព ដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។

## ២.១.៣. អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩

- **មាត្រា១ :** កុមារ គឺមនុស្សគ្រប់រូបដែលមានអាយុតិចជាង១៨ឆ្នាំ។
- **មាត្រា៥ :** រដ្ឋភាគីត្រូវគោរពដល់ការទទួលខុសត្រូវ គោរពសិទ្ធិ និងគោរពករណីយកិច្ចរបស់ឪពុកម្តាយ ឬរបស់សមាជិកគ្រួសារដែលជាសាច់ញាតិឆ្ងាយៗបើប្រសិនមាន ឬសមាជិកនៃសហគមន៍ ដែលតាមទំនៀមទម្លាប់ប្រចាំភូមិស្រុក គេចាត់ឱ្យមានអ្នកអាណាព្យាបាលស្របច្បាប់ ឬអ្នកឯទៀតដែលទទួលខុសត្រូវតាមច្បាប់លើកុមារ នៅក្នុងការផ្តល់ដល់កុមារតាមរបៀបមួយ ដែលស៊ីគ្នាទៅនឹងការចម្រើនលូតលាស់នៃសមត្ថភាពរបស់កុមារ នូវការដឹកនាំ និងដំបូន្មានសមស្របទៅនឹងការប្រើប្រាស់សិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់ដោយអនុសញ្ញានេះ។
- **មាត្រា១៩ :** រដ្ឋជាភាគីប្រកាន់យកវិធានការសមស្របទាំងអស់ ខាងផ្នែកច្បាប់ ផ្នែករដ្ឋបាល សង្គម និងផ្នែកអប់រំ ដើម្បីការពារតទល់នឹងរាល់ទម្រង់នៃភាពហិង្សាដែលប៉ះពាល់រាងកាយ ឬគំនិតបញ្ញា ការមានរបួស ការបំពាន ការបោះបង់ចោល ឬការមិនគិតគូរដល់ ការធ្វើបាប ឬការជិះជាន់ រួមទាំងការបំពារបំពានខាងផ្លូវភេទផងដែរ ក្នុងពេលដែលកុមារស្ថិតនៅក្រោមការចិញ្ចឹមបីបាច់របស់ឪពុក ឬម្តាយ ឬ(ទាំងឪពុកម្តាយ) ឬអ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវក្នុងការថែទាំកុមារនោះ។

## ២.១.៤. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- **មាត្រា៣១ :** ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងជាមួយនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។
- **មាត្រា៣២ :** ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។
- **មាត្រា៣៨ :** ច្បាប់ហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។
  ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។
- **មាត្រា៤៧ :** មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។
  កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។
- **មាត្រា៤៨ :** រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។

  រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

## ២.១.៥. បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅកម្ពុជា ក្នុងសម័យអន្តរកាល (ឆ្នាំ១៩៩២)

**មាត្រា៣១ : ឃាតកម្មគិតទុកជាមុន**

១). ជនណាដែលសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី១០ឆ្នាំ ទៅ២០ឆ្នាំ។

២). ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ។ ការពួនស្ទាក់ គឺការឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយ ដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលនោះ។

**មាត្រា៣២ : អំពើមនុស្សឃាតដោយចេតនា**

ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតដោយចេតនា ដោយគ្មានស្ថានទម្ងន់ណាមួយដែលចែងក្នុងមាត្រា៣១ ដោយបានប្រើឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី ៨ឆ្នាំ ទៅ១៥ឆ្នាំ។

**មាត្រា៣៣ : បទរំលោភសេពសន្ថវៈ**

១). ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើជនម្នាក់ទៀត ទោះភេទដូចគ្នាឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋ ពី៥ឆ្នាំ ទៅ១០ឆ្នាំ។

២). បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិ ដោយឃោរឃៅ ដោយបង្ខំឬដោយមិនដឹងខ្លួនជាមុន។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើង ដោយជនណាដែលមានអំណាចលើជនរងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្ត គឺដាក់គុកជាបទឧក្រិដ្ឋ ពី១០ឆ្នាំ ទៅ១៥ឆ្នាំ។

**មាត្រា៣៥ : ការបង្ខាំងមនុស្សដោយខុសច្បាប់**

ជនណាដែលបានចាប់ខ្លួន ឬឃុំខ្លួនមនុស្សម្នាក់ ឬច្រើននាក់ ដោយគ្មានបញ្ជាពីអាជ្ញាធរតុលាការត្រូវមានទោស ÷

- ដាក់គុកជាបទឧក្រិដ្ឋ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈពេលលើសពី១ខែ
- ដាក់គុកពី៣ឆ្នាំ ទៅ៥ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈពេលតិចជាង១ខែ

**មាត្រា៤០ : អំពើមនុស្សឃាតដោយអចេតនា**

ជនណាដោយខ្វះការប្រុងប្រយ័ត្ន ដោយការធ្វេសប្រហែស ដោយមិនប្រយ័ត្ន ឬដោយមិនគោរពតាមបទបញ្ជា ធ្វើឱ្យស្លាប់ជនម្នាក់ទៀតដោយគ្មានចេតនា ត្រូវមានទោសពីបទមជ្ឈិមធ្វើមនុស្សឃាតដោយអចេតនា ហើយផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ដល់៣ឆ្នាំ ។

**មាត្រា៤១ : អំពើបង្ករបួសស្នាម**

ជនណាវាយតប់បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នក្នុងរយៈពេលលើសពី៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសស្នាមដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៥ឆ្នាំ ។

- បើពិការភាពបណ្តោះអាសន្ននោះតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី៦ខែដល់២ឆ្នាំ ។
- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទា គឺដាក់គុកពី២ខែ ទៅ១ឆ្នាំ ។
- បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កម្រិតទោសត្រូវទ្វេមួយជាពីរ ។

**មាត្រា៤២ : អំពើបៀតបៀនកេរ្តិ៍ខ្មាស**

១). ជនណាដែលបៀតបៀនដល់កេរ្តិ៍ខ្មាសនៃជនណាម្នាក់ទៀត ដែលមានភេទដូចគ្នា ឬមិនដូចគ្នា ដោយប្រព្រឹត្តទៅលើជននោះ តាមការស្ទាប អង្អែល ឬអំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ ត្រូវមានទោសពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៣ឆ្នាំ ។

២). បើការបៀតបៀនដល់កេរ្តិ៍ខ្មាសនោះ ធ្វើឡើងដោយការបន្លំ ដោយអំពើហិង្សា ដោយការគំរាមកំហែង បើអ្នករងគ្រោះមានអាយុតិចជាង១៦ឆ្នាំ ឬអ្នកប្រព្រឹត្តនោះជាអ្នកមានអំណាចលើជនរងគ្រោះ កម្រិតផ្តន្ទាទោសទ្វេជាពីរ ។

**មាត្រា៥២ : ការធ្វើឱ្យខូចខាតដោយចេតនា**

ជនណាដែលធ្វើឱ្យខូចខាត ឬប៉ុនប៉ងធ្វើឱ្យខូចខាតដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃ ត្រូវមានទោសមជ្ឈិមពីបទធ្វើឱ្យខូចខាតដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ដល់៣ឆ្នាំ ។ បើការខូចខាតនោះមានលក្ខណៈស្រាល ឬទ្រព្យនោះមានតម្លៃតិចតួច ទោសដាក់គុកត្រូវបញ្ចុះមកត្រឹម២ខែ ទៅ១ឆ្នាំ ។

**មាត្រា៥៣ : អំពើបង្កអគ្គិភ័យដោយចេតនា**

១). ជនណាដែលធ្វើឱ្យខូចខាត ឬប៉ុនប៉ងធ្វើឱ្យខូចខាតដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃ ដោយបង្កអគ្គិភ័យ ដោយប្រើជាតិផ្ទុះ ត្រូវមានទោសមជ្ឈិមពីបទបង្កអគ្គិភ័យ ដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ដល់៣ឆ្នាំ ។

២). បើទ្រព្យដែលភ្លើងឆេះនោះ ជាទ្រព្យដែលមានមនុស្សអាស្រ័យនៅពី១នាក់ ទៅច្រើននាក់ កម្រិតកំណត់ទណ្ឌកម្មនឹងត្រូវទ្វេមួយជាពីរ ។

### ២.១.៦. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

- **មាត្រា២៩ :** ក្នុងគ្រួសារ ប្តី ប្រពន្ធ ត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ។
- **មាត្រា៣០ :** ប្តី ប្រពន្ធ មានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល។
- **មាត្រា៣២ :** ប្រពន្ធ និង ប្តី មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម។
- **មាត្រា៣៧ :** ទ្រព្យសម្បត្តិរួមអាចលក់ដូរ ឬធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងពីសហព័ទ្ធទាំងពីរ។
- **មាត្រា៧១ :** ប្រសិនបើទ្រព្យសម្បត្តិផ្ទាល់របស់សហព័ទ្ធម្នាក់ត្រូវសហព័ទ្ធម្នាក់ទៀតបំផ្លាញ សហព័ទ្ធនេះត្រូវតែសងតម្លៃទ្រព្យនោះវិញ។
- **មាត្រា១១៥ :** ឪពុក ម្តាយមានករណីយកិច្ចត្រូវស្រឡាញ់កូន ចិញ្ចឹមបីបាច់រក្សាកូន និងយកចិត្តទុកដាក់អប់រំកូន គឺបណ្តុះគំនិតកូនឱ្យស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតីសាមគ្គីអន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ គោរពសិទ្ធិ និងទ្រព្យសម្បត្តិរបស់អ្នកដទៃ។

  កូនមានករណីយកិច្ចត្រូវស្រឡាញ់ និង គោរពឪពុកម្តាយ ថែទាំរក្សាឪពុកម្តាយ និងផ្គត់ផ្គង់សេចក្តីត្រូវការរបស់ឪពុកម្តាយ។
- **មាត្រា១១៦ :** ឪពុក ម្តាយ មិនត្រូវធ្វើបាបកូនរបស់ខ្លួន កូនប្រសា កូនចិញ្ចឹម ឬកូនរបស់ប្តី ឬរបស់ប្រពន្ធមុនឡើយ។

### ២.១.៧. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា ១ .-

ច្បាប់នេះ មានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះ មានទិសដៅបង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន។

# ជំពូកទី២
# វិសាលភាពនៃការអនុវត្ត

មាត្រា ២ .-

អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ :

១. ប្ដី ឬប្រពន្ធ

២. កូនក្នុងបន្ទុក

៣. ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ ។

មាត្រា ៣ .-

អំពើហិង្សាក្នុងគ្រួសារ ទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុត ដើម្បីការពារជនរងគ្រោះ ឬជនអាចនឹងរងគ្រោះ ។

អំពើហិង្សារួមមាន :

- ការប៉ះពាល់ដល់ជីវិត
- ការប៉ះពាល់ដល់បូរណភាពរូបកាយ
- ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ
- ការឈ្លានពានខាងផ្លូវភេទ ។

មាត្រា ៤ .-

អំពើប៉ះពាល់ដល់ជីវិត រួមមាន :

- មនុស្សឃាតដោយគិតទុកជាមុន
- មនុស្សឃាតដោយចេតនា
- មនុស្សឃាតដោយអចេតនា បណ្ដាលមកពីអំពើចេតនាផ្សេងទៀតនៃជនល្មើស
- មនុស្សឃាតដោយអចេតនា ។

មាត្រា ៥ .-

អំពើប៉ះពាល់ដល់បូរណភាពរូបកាយ រួមមាន :

- ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬ ឥតអាវុធ មានរបួស ឬគ្មានរបួស
- ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ ។

មាត្រា ៦ .-

អំពើទារុណកម្ម ឬអំពើឃោរឃៅ រួមមាន :

- ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ
- ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់ ។

មាត្រា ៧ ..

អំពើឈ្លានពានខាងផ្លូវភេទ រួមមាន :

- ការប្រើហិង្សាសេពសន្ថវៈ
- ការបៀតបៀនកេរ្តិ៍ខ្មាស
- ការធ្វើអាស្រូវភាស ។

មាត្រា ៨ ..

ត្រូវទប់ស្កាត់ផងដែរចំពោះអំពើគំរាមកំហែងក្នុងគោលបំណងធ្វើឱ្យជនរងគ្រោះ ភ័យខ្លាច តក់ស្លុត និង អំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារតែមួយ ។

មិនរាប់បញ្ចូលថាជាការប្រើហិង្សាឬសកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬធ្វើការដាស់តឿនក្រើនរំលឹក ឬចាត់វិធានការនានាសមស្រប ដើម្បីឱ្យសហព័ទ្ធ ឬកូន ឬអ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការប្រៀនប្រដៅ និងការអប់រំនោះធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌ និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី៣
## សមត្ថកិច្ច និងនីតិវិធី

មាត្រា ៩ ..

អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬបម្រុងនឹងកើតឡើង ដើម្បីទប់ស្កាត់ និងការពារជនរងគ្រោះ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

មាត្រា ១០ ..

ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មន្ត្រីនៃក្រសួងកិច្ចការនារីបម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់នេះ ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះ ស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

មាត្រា ១១ ..

ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះ មន្ត្រីសមត្ថកិច្ចដទៃទៀត រួមមាន មន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេភូមិ ដែលបានធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ ត្រូវបានទទួលអំណាចពីច្បាប់នេះ ដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការ ។ កំណត់ហេតុនេះ មានតម្លៃស្មើគ្នាដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ ។

មាត្រា ១២ .-

ក្នុងការអនុវត្តភារកិច្ច អាជ្ញាធរមានសមត្ថកិច្ចដូចបានចែងក្នុងមាត្រា៩ មាត្រា១០ និងមាត្រា១១ ខាងលើនេះ ត្រូវគោរពតាមនីតិវិធីដែលបានកំណត់ក្នុងបញ្ញត្តិនៃច្បាប់នេះ និងនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី៤

## វិធានការទប់ស្កាត់ និងការការពារជនរងគ្រោះ

មាត្រា ១៣ .-

ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើតឬជឿជាក់ថានឹងកើតឡើង អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយ :

- ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែងដែលជនមុខសញ្ញាបាន ឬអាចប្រើប្រាស់
- បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះ បើមានការស្នើសុំពីជនរងគ្រោះ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។
- ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្នដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់ ។
- ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងនៅក្នុងមាត្រា២០ និងមាត្រា២៦នៃច្បាប់នេះ ។

**ជនមុខសញ្ញា**ក្នុងច្បាប់នេះ គឺសំដៅដល់អ្នកដែលបានប្រព្រឹត្ត កំពុងប្រព្រឹត្ត និងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ។

មាត្រា ១៤ .-

ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចរដ្ឋបាលស្របតាមមាត្រា៤៣ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចាត់វិធានការបណ្តោះអាសន្នស្របច្បាប់ដែលមានជាអាទិ៍ :

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ
- ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច
- ចាត់វិធានការស្របច្បាប់ផ្សេងទៀត ដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ ។

**មាត្រា ១៥ ..**

បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើតឡើងហើយ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅក្នុងទីកន្លែងកើតហេតុ ទោះជាពុំមានដីកាតុលាការអនុញ្ញាតឱ្យចូលក៏ដោយ ក្នុងករណីទាំងឡាយណាដែលមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ច យល់ដោយសមហេតុផលថាមានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល៤៨ម៉ោងកន្លងផុត ឬនឹងអាចកើតឡើងក្នុងអំឡុងពេល២៤ម៉ោងខាងមុខ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

**មាត្រា ១៦ ..**

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឱ្យចេញដីកាការពារ ។

ចៅក្រមដែលទទួលចាត់ការ ត្រូវចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានជនមុខសញ្ញា ។

**មាត្រា ១៧ ..**

ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ ដើម្បីផ្សះផ្សា ឬសម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរបានទេ ។

**មាត្រា ១៨ ..**

អាជ្ញាធរមានសមត្ថកិច្ច អាចឃាត់ខ្លួនជនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការ ដូចមានចែងក្នុងមាត្រា២៤ និងមាត្រា២៥ នៃច្បាប់នេះ ដោយពុំចាំបាច់មានដីកាតុលាការ ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ដែលពុំមានដីកាពីតុលាការ ត្រូវហាមឃាត់ ។

ក្នុងករណីអនុវត្តតាមបញ្ញត្តិនៃវាក្យខណ្ឌទី១ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់ កសាងសំណុំរឿង និងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ ក្នុងអំឡុងពេលអតិបរមាដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីចាត់វិធានការបន្ថែមឱ្យស្របច្បាប់ ។

**មាត្រា ១៩ ..**

អំពើហិង្សាក្នុងគ្រួសារណាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈជាបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ទោះអំពើហិង្សានេះបានកន្លងផុតហើយក៏ដោយ ។

បណ្តឹងអាជ្ញាត្រូវធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់នេះ និងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

# ជំពូកទី៥
# សិទ្ធិអំណាចតុលាការ

**មាត្រា ២០ .-**

ដីកាការពារមានអានុភាពបង្គាប់បញ្ជាលើជនមុខសញ្ញា លើអាជ្ញាធរមានសមត្ថកិច្ច និងលើជនដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ។ ដីកាការពារនេះ ជាវិធានការផ្នែករដ្ឋប្បវេណី ។

ដីកាការពារមានកម្មវត្ថុចង្អុលបង្ហាញអំពីស្ថានភាព សកម្មភាព ឬអាកប្បកិរិយាទាំងអស់ជាការបង្គាប់ឱ្យធ្វើក្តី ឬបញ្ជាហាមឃាត់ទង្វើក្តី ដែលទាក់ទិនទៅនឹងតម្រូវការការពារជនរងគ្រោះ ឬបុគ្គលណាដែលទទួលការគំរាមកំហែងពីអំពើហិង្សាក្នុងគ្រួសារ ។

ដីកាការពារមាន :

១. ឥទ្ធិពលសម្រាប់មួយរយៈ

២. ឥទ្ធិពលបណ្តោះអាសន្នស្របតាមបញ្ញត្តិនៃមាត្រា២៣នៃច្បាប់នេះ ។

ចៅក្រមមានសមត្ថកិច្ចមានសិទ្ធិចេញដីកាការពារជាថ្មី ស្របតាមស្ថានភាពជាក់ស្តែង ឬបទបញ្ជាណាមួយក្នុងលក្ខណៈសមស្រប ។

**មាត្រា ២១ .-**

មានតែតុលាការខេត្ត ក្រុងទេ ដែលមានសមត្ថកិច្ចចេញដីកាការពារជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នាជាផ្នែកស៊ីវិលក្តី ជាផ្នែករដ្ឋបាលក្តី ឬជាផ្នែកព្រហ្មទណ្ឌក្តី ។

**មាត្រា ២២ .-**

ពាក្យបណ្តឹងសុំដីកាការពារពីតុលាការអាចធ្វើឡើងដោយ :

១. ជនរងគ្រោះ ឬតំណាងជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ ។

២. ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន ។

**មាត្រា ២៣ .-**

ដីកាការពារមានពីរដំណាក់កាល :

១. ដំណាក់កាលទី១ ហៅថាដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល២(ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ ។

២. ដំណាក់កាលទី២ ហៅថាដីកាការពារមានរយៈពេល៦(ប្រាំមួយ)ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬមុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៤ .-**

តុលាការអាចចេញដីកាការពារបណ្តោះអាសន្ន នៅពេលទទួលបណ្តឹងការពារ ដោយមិនចាំបាច់សាកសួរជនមុខសញ្ញា បើសិនវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាពនិងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៥ .-**

ក្នុងការចេញដីកាការពារ តុលាការមានសិទ្ធិកំណត់បញ្ហាលើសកម្មភាពជនមុខសញ្ញា ដើម្បីការពារជនរងគ្រោះដូចតទៅ :

- ហាមប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង
- ហាមចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះនិងអាជ្ញាធរមានសមត្ថកិច្ច
- ហាមជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះតាមផ្លូវណាមួយ
- ហាមបំផ្លាញទ្រព្យ ឬចាត់ចែងលក់ទ្រព្យរបស់ជនរងគ្រោះឬញាតិសាលោហិតរបស់ជនរងគ្រោះ
- បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬបំបែកជនរងគ្រោះបើមានការស្នើសុំ ។ ក្នុងករណីពិសេសជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

បើយល់ថាជាការចាំបាច់សម្រាប់ការពារ ឬរៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ដោយចាត់វិធានការបន្ថែមទៀតដូចតទៅ :

- បញ្ជាឱ្យភ្នាក់ងារនគរបាល ឬកងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ
- សម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយគិតយ៉ាងខ្ពស់បំផុតពីសិទ្ធិ និងផលប្រយោជន៍នៃកុមារនោះ
- បញ្ចប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះចំពោះជនមុខសញ្ញា
- កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុឱ្យជនរងគ្រោះ ដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា ។

**មាត្រា ២៦ .-**

ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ការផ្សះផ្សា ឬសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង ។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយ ដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា៤៥នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧ .-**

អនុលោមលើខ្លឹមសារនៃមាត្រា២៥ខាងលើ តុលាការត្រូវព្យាយាមធ្វើការផ្សះផ្សាភាគីមានវិបត្តិអំពើហិង្សាក្នុងលក្ខខណ្ឌឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សមាជិកនៃគ្រួសារនោះ ។ ក្នុងការផ្សះផ្សាសម្រុះសម្រួលគ្នា តុលាការត្រូវចៀសវាងធ្វើសម្ពាធលើគូភាគីដែលមិនព្រមស្រុះស្រួលគ្នា ឬបង្ខិតបង្ខំភាគីណាមួយឱ្យចូលផ្សះផ្សា ឬបង្ខិតបង្ខំឱ្យចុះកិច្ចព្រមព្រៀងដោយគ្មានការព្រមព្រៀងពីភាគីទាំងពីរឡើយ ។

**មាត្រា ២៨ .-**

ក្នុងករណីអំពើហិង្សាពាក់ព័ន្ធដល់កុមារ អាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីទទួលបន្ទុកបម្រើប្រយោជន៍កុមារនិងការពារសុខុមាលភាពកុមារ ធ្វើការតាមដានបញ្ហានេះ ។ ក្នុងករណីធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងទៅតុលាការ ។

អ្នកទទួលខុសត្រូវណាម្នាក់ដែលតុលាការបានបង្គាប់រួមទាំងព្រះរាជអាជ្ញាផង ត្រូវទទួលបន្ទុកតាមដានអំពីស្ថានភាពនៃកុមារ និងធ្វើសេចក្ដីរាយការណ៍អំពីស្ថានភាពនេះជូនទៅតុលាការ ។

តុលាការអាចផ្ដល់អាណត្តិដល់ស្ថាប័នមានសមត្ថកិច្ច ដើម្បីរកជំនួយនិងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារព្រមទាំងការពារសុវត្ថិភាពនិងសុខុមាលភាពជនរងគ្រោះ ពេលតុលាការកំពុងបំពេញនីតិវិធី ។

**មាត្រា ២៩ .-**

លើកលែងតែករណីបន្ទាន់ដូចមានចែងក្នុងមាត្រា២៣ តុលាការត្រូវជូនដំណឹងទៅជនមុខសញ្ញាអំពីការស្នើសុំដីកាការពារមិនឱ្យលើសពី៥(ប្រាំ)ថ្ងៃ មុននឹងយកបញ្ហានេះមកពិនិត្យ ។ បើជនមុខសញ្ញានេះមិនបង្ហាញខ្លួននៅមុខតុលាការ ដើម្បីបញ្ជាក់អំពីហេតុផល តុលាការអាចពិនិត្យបញ្ហាដោយពុំមានវត្តមានជនមុខសញ្ញា ឬបើជាការចាំបាច់អាចចាត់វិធានការតាមនីតិវិធីជាធរមាន ចំពោះជនមុខសញ្ញាដែលមិនអើពើនឹងសេចក្ដីសម្រេចរបស់តុលាការ ។

ក្នុងករណីអវត្តមាន ឬការមិនអើពើរបស់ជនមុខសញ្ញាអំពីសេចក្ដីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវស្នើតុលាការចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣០ .-**

បើមានសំណើពីភាគីណាមួយ តុលាការអាចកែប្រែ លុបចេញ ឬបន្ថែមទម្ងន់នៅក្នុងដីកាការពារក្រោយពីបានជូនដំណឹងទៅភាគីម្ខាងទៀត ៥ (ប្រាំ) ថ្ងៃ មុននឹងសម្រេច ។

គូភាគីអាចធ្វើការតវ៉ាឱ្យតុលាការពិនិត្យឡើងវិញលើសេចក្ដីសម្រេចរបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរ ២(ពីរ) ខែ ចាប់ពីថ្ងៃចេញដីកាការពារ ។

**មាត្រា ៣១ .-**

ជនរងគ្រោះ និងជនមុខសញ្ញាមានសិទ្ធិទទួលអ្នកការពារតាមផ្លូវច្បាប់ ឬមានសិទ្ធិជ្រើសរើសអ្នកតំណាងដែលខ្លួនទុកចិត្ត នៅគ្រប់ដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៣២ .-**

ក្រោយពីបានចេញដីកាការពាររួចហើយ ព្រះរាជអាជ្ញា ឬមន្ត្រីមានសមត្ថកិច្ចដែលច្បាប់ប្រគល់ឱ្យត្រូវចាត់គ្រប់វិធានការ ដើម្បីអនុវត្តដីកាការពារតាមនីតិវិធីកំណត់។

## ជំពូកទី ៦

## ការអប់រំ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល

**មាត្រា ៣៣ .-**

រដ្ឋ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទូទាំងប្រទេសបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះ ជាពិសេសអំពីការទទួលខុសត្រូវក្នុងគ្រួសារ ការគោរពសិទ្ធិគ្នាទៅវិញទៅមកដើម្បីលើកស្ទួយតម្លៃគ្រួសារខ្មែរ សីលធម៌ សុជីវធម៌ ការរស់នៅ ការថែរក្សា និងការអប់រំគ្រួសារ របៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធី ព្រមទាំងណែនាំឱ្យយល់ពីវិធានការទាំងឡាយក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារដល់ជនរងគ្រោះ។

រដ្ឋជំរុញភាគីដែលមានវិបត្តិអំពើហិង្សាក្នុងគ្រួសារឱ្យចូលរួមក្នុងវគ្គពិគ្រោះបញ្ហា ដើម្បីរៀនសូត្រស្វែងយល់អំពីវិធីសាស្ត្រនានា ក្នុងការដោះស្រាយទំនាស់ និងអប់រំដោយមិនប្រើប្រាស់អំពើហិង្សា។

**មាត្រា ៣៤ .-**

ក្រសួង ស្ថាប័នទាំងឡាយរបស់រដ្ឋត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការនានា និងផ្នែកឯកជន ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

មន្ត្រីពាក់ព័ន្ធទាំងឡាយ និងភ្នាក់ងារអង្គការនានាត្រូវបានទទួលការបណ្តុះបណ្តាលអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ និងវិធានការទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ ដើម្បីឱ្យយល់ពីមូលហេតុចម្បងនានាដែលបង្កឱ្យមានការកើតឡើងនូវអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសទាំងឡាយដែលពាក់ព័ន្ធវិស័យនេះ។

## ជំពូកទី៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥ .-**

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

**មាត្រា ៣៦ .-**

ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជាទីតិជន ដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀត

ដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧ ..**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

នស/រកម/១០០៥/០៣១

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ហត្ថលេខា**

**អ៊ឹង កន្ថាផាវី**

លេខ ៤២៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវឃី តាន់**

## ២.២. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

### ២.២.១. តួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៦ មាត្រ៣៨ មាត្រា៤០ និងមាត្រា៤១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ **ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌** រួមមាន ÷

- ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត "នៅក្នុងភារកិច្ចតែប៉ុណ្ណោះ"
- អភិបាល-អភិបាលរងខេត្តក្រុង អភិបាល-អភិបាលរងស្រុកខណ្ឌ និងមេឃុំ ចៅសង្កាត់
- ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកនៃ ÷
  - នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
  - នាយកដ្ឋាននគរបាលសេដ្ឋកិច្ច
  - នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ
  - នាយកដ្ឋានប្រឆាំងភេរវកម្ម
  - នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
  - នាយកដ្ឋានជនបរទេស
  - មន្ទីរប្រឆាំងគ្រឿងញៀន
- ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង
- ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា ÷
  - ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់
  - ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល
  - ការិយាល័យនគរបាលសេដ្ឋកិច្ច
  - ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
  - ការិយាល័យប្រឆាំងគ្រឿងញៀន
  - ការិយាល័យប្រឆាំងភេរវកម្ម
  - ការិយាល័យជនបរទេស
- អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ
- ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ និងប្រធាន អនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"
- ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ចំពោះបទល្មើសព្រហ្មទណ្ឌ

- មេបញ្ជាការ មេបញ្ជាការរង ព្រមទាំងមន្ត្រីចាប់ពីអនុប្រធានផ្នែកឡើងនៃកងរាជអាវុធហត្ថ ដែលទទួលការងារព្រហ្មទណ្ឌ "ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងកិច្ចការយោធា"
- មន្ត្រីនៃក្រសួង ឬស្ថាប័នណាដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើស ។

ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការដឹកនាំ និងសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និងវិធានការស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិប្រគល់ទៅមន្ត្រីនគរបាលយុត្តិធម៌ នូវសមត្ថកិច្ចណាមួយដែលមានវិសាលភាពលើដែនដីទាំងមូល ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញប្រកាសណែនាំអំពីរបៀបរបបធ្វើការងារ និងនីតិវិធីខាងផ្លូវរដ្ឋបាលដល់មន្ត្រីនគរបាលយុត្តិធម៌ ។

អភិបាល អភិបាលរងខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចបញ្ជា ណែនាំមន្ត្រីនគរបាលយុត្តិធម៌ដែលស្ថិតក្នុងរង្វង់ដែនដីរបស់ខ្លួន ឱ្យធ្វើប្រតិបត្តិការលើបទល្មើស ហើយប្រតិបត្តិការទាំងឡាយ ត្រូវមានការសហការពីព្រះរាជអាជ្ញា ។

មាត្រា៣៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៦ មាត្រា៣៨ មាត្រា៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ **មន្ត្រីនគរបាលយុត្តិធម៌ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖**

១). ទទួលពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ទាក់ទងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុនានា

២). ចាត់ចែងប្រមូលភស្តុតាងនានា

៣). អាចស្នើសុំជំនួយពីកម្លាំងសាធារណៈ

៤). ធ្វើកំណត់ហេតុ

៥). អាចទទួលលិខិតបង្គាប់ឱ្យសួរជំនួស

៦). អាចសម្រេចឃាត់ខ្លួនបានរយៈពេល **៤៨ម៉ោងយ៉ាងយូរ**

៧). ក្នុងករណីរឿងឧក្រិដ្ឋ និងមជ្ឈិមជាក់ស្តែង អាចសួរយកចម្លើយសាក្សី ធ្វើការឆែកឆេរ និងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសម្រេចឃាត់ខ្លួនជនល្មើស "**៤៨ម៉ោងយ៉ាងយូរ**" ឃាត់ខ្លួនបុគ្គលណាមួយប្រសិនបើមានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់សមស្របធ្វើការចោទប្រកាន់បាន ។

៨). មន្ត្រីនគរបាលយុត្តិធម៌ អាចសុំពន្យារពេលឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេលមិនលើសពី២៤ ម៉ោង ដោយមិនគិតពីថេរវេលាចាំបាច់នៃការដឹកជញ្ជូនក្នុងល័ក្ខខ័ណ្ឌទាំង៥ ដូចខាងក្រោម :

- បទឧក្រិដ្ឋធ្ងន់ធ្ងរ

- មានតម្រុយចង្អុលបង្ហាញច្បាស់ថាបានប្រព្រឹត្តបទល្មើស
- ជាវិធានការចាំបាច់ ដើម្បីធ្វើឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ
- ពាក្យសុំត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពសមហេតុផល
- មានចំណារយល់ព្រមពីព្រះរាជអាជ្ញា ។ ការអនុញ្ញាតឱ្យពន្យារត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ។

៩). ការពន្យារមិនអាចត្រូវយល់ព្រមបានទេចំពោះបុគ្គលដែលត្រូវឃាត់ខ្លួននោះមានអាយុតិចជាង១៨ឆ្នាំ

១០). អនីតិជនដែលមានអាយុតិចជាង១៣ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនដល់៣៦ម៉ោងឡើយ ។

## ២.២.២. តួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានទួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ចំពោះមុខសាលាជំនុំជម្រះរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញា ត្រូវជា **"គូក្តីដើមជានិច្ច"**។ ក្នុងន័យនេះ ព្រះរាជអាជ្ញាធ្វើបណ្តឹងអាជ្ញា ដោយចោទប្រកាន់ជនជាប់ចោទ និងសុំឱ្យអនុវត្តច្បាប់លើជននោះ ។
- បន្ទាប់ពីបានដឹងថា មានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយភ្លាម ព្រះរាជអាជ្ញាត្រូវចាត់វិធានការស៊ើបអង្កេតដែលច្បាប់បានប្រគល់ឱ្យខ្លួន និងជាវិធានការចាំបាច់នៅក្នុងការរកឱ្យឃើញនូវការពិត ។
- មានបេសកកម្ម ត្រូវទទួលពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារដែលទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។ ទោះជាពាក្យនោះចេញមកពីជនណាម្នាក់ ចេញមកពីមន្ត្រីនគរបាលយុត្តិធម៌ ឬក៏ចេញពីមន្ត្រីឯទៀតដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌក៏ដោយ ។
- មានបេសកកម្មទទួលកំណត់ហេតុធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលពិនិត្យបញ្ជាក់បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។
- មានបេសកកម្មធ្វើដោយខ្លួនឯងនូវការស៊ើបអង្កេតបឋម បានតែក្នុងករណីបទឧក្រិដ្ឋ និងមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ។
- មានបេសកកម្មកេណ្ឌកម្លាំងសាធារណៈ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

## ២.២.៣. តួនាទី និងភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច

អាជ្ញាធរមានសមត្ថកិច្ចដែលចែងនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មាន ÷

- មន្ត្រីដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ (នគរបាលយុត្តិធម៌)
- មន្ត្រីនគរបាល និងភ្នាក់ងារនគរបាល
- កងរាជអាវុធហត្ថ
- មេឃុំ ចៅសង្កាត់ និងមេភូមិ

**អាជ្ញាធរមានសមត្ថកិច្ច មានភារកិច្ច :**

- ធ្វើអន្តរាគមន៍ជាបន្ទាន់ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬបម្រុងនឹងកើតឡើង ដើម្បីទប់ស្កាត់ និងការពារជនរងគ្រោះ ដោយ :
  - ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែងដែលជនមុខសញ្ញាបានឬអាចប្រើប្រាស់ (**មន្ត្រីនគរបាលយុត្តិធម៌**) ។
  - បង្វែរជនមុខសញ្ញាចេញពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះ បើមានការស្នើសុំពីជនរងគ្រោះ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចត្រូវបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ (**អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌**) ។
  - ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្ន ដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់ (**អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌**) ។
  - ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះ អំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សា (**អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌**) ។
- ធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីករណីអំពើហិង្សា ក្នុងគ្រួសារដែលបានកើតឡើងជូនតុលាការ ។ ក្នុងករណីបន្ទាន់ ត្រូវរាយការណ៍ជូនទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច (**អាជ្ញាធរមានសមត្ថកិច្ច**) ។
- អាចចេញសេចក្តីសម្រេចរដ្ឋបាល ដើម្បីការពារសន្តិសុខជនរងគ្រោះ (**មេឃុំ ចៅសង្កាត់**) ។
- អាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឱ្យចេញដីកាការពារ (**អាជ្ញាធរមានសមត្ថកិច្ច**) ។
- អាចឃាត់ខ្លួនជនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការ ដូចមានចែងក្នុងមាត្រា២៤ និងមាត្រា២៥ នៃច្បាប់នេះ ដោយពុំចាំបាច់មានដីកាតុលាការ (**មន្ត្រីនគរបាលយុត្តិធម៌**) ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ដែលពុំមានដីកាពីតុលាការត្រូវហាមឃាត់ ។
- អាចធ្វើជាអ្នកអាជ្ញាកណ្តាលក្នុងការផ្សះផ្សា ឬសម្រុះសម្រួលទៅតាមការយល់ព្រមពីភាគីទាំងសងខាងចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ (**អាជ្ញាធរមានសមត្ថកិច្ច**) ។
- ក្នុងករណីអំពើហិង្សាពាក់ព័ន្ធដល់កុមារ អាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីទទួលបន្ទុកបម្រើប្រយោជន៍កុមារ និងការពារសុខុមាលភាពកុមារ ធ្វើការតាមដានបញ្ហានេះ ។ ក្នុងករណីធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ច ត្រូវកសាងសំណុំរឿងទៅតុលាការ (**មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីចាត់តាំងដោយតុលាការ**) ។

- អ្នកទទួលខុសត្រូវណាម្នាក់ដែលតុលាការបានបង្គាប់ រួមទាំងព្រះរាជអាជ្ញាផង ត្រូវទទួលបន្ទុកតាមដានអំពីស្ថានភាពនៃកុមារ និងធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនេះជូនទៅតុលាការ (**មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីចាត់តាំងដោយតុលាការ**)។
- ក្នុងករណីអវត្តមាន ឬការមិនអើពើរបស់ជនមុខសញ្ញាអំពីសេចក្តីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវស្នើឱ្យតុលាការចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន (**មន្ត្រីនគរបាលយុត្តិធម៌**)។
- ក្រោយពីបានចេញដីកាការពាររួចហើយ ព្រះរាជអាជ្ញាឬមន្ត្រីមានសមត្ថកិច្ចដែលច្បាប់ប្រគល់ឱ្យត្រូវចាត់គ្រប់វិធានការ ដើម្បីអនុវត្តដីកាការពារតាមនីតិវិធីកំណត់ (**ព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌**)។

## ២.២.៤. តួនាទី និងភារកិច្ចរបស់មន្ត្រីក្រសួងកិច្ចការនារី

- ធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីករណីអំពើហិង្សា ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌។ កំណត់ហេតុនេះ មានតម្លៃស្មើគ្នាដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ។
- អាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឱ្យចេញដីកាការពារ។

## ២.២.៥. តួនាទី និងភារកិច្ចរបស់សហគមន៍

- ផ្តល់ដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត
- បញ្ជូនជនរងគ្រោះទៅកាន់សេវាសុខភាព
- ធ្វើជាអ្នកអាជ្ញាកណ្តាលក្នុងការផ្សះផ្សា ឬសម្រុះសម្រួលទៅតាមការយល់ព្រមពីភាគីទាំងសងខាងចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាលឬបទលហុ។
- ឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះទាំងស្មារតី និងសម្ភារតាមការស្ម័គ្រចិត្ត។

## គំនូសបំព្រួញនៃដំណើរការដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ



## ២.៣. ដីកាការពារ

### ២.៣.១. និយមន័យ

ដីកាការពារមានអានុភាពបង្គាប់បញ្ជាលើជនមុខសញ្ញា លើអាជ្ញាធរមានសមត្ថកិច្ច និងលើជនដែលពាក់ព័ន្ធនឹងរឿងក្តីករណីអំពើហិង្សាក្នុងគ្រួសារ ។ ដីកាការពារនេះ ជាវិធានការផ្នែករដ្ឋប្បវេណី ។

ដីកាការពារមានកម្មវត្ថុចង្អុលបង្ហាញអំពីស្ថានភាព សកម្មភាព ឬអាកប្បកិរិយាទាំងអស់ ជាការបង្គាប់ឱ្យធ្វើក្តី ឬបញ្ជាហាមឃាត់ទង្វើក្តី ដែលទាក់ទិនទៅនឹងតម្រូវការការពារជនរងគ្រោះ ឬបុគ្គលណាដែលទទួលការគំរាមកំហែងពីអំពើហិង្សាក្នុងគ្រួសារ ។

ដីកាការពារមាន ÷

- ឥទ្ធិពលសម្រាប់មួយរយៈ
- ឥទ្ធិពលបណ្តោះអាសន្នស្របតាមបញ្ញត្តិនៃមាត្រា២៣ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

ចៅក្រមមានសមត្ថកិច្ច មានសិទ្ធិចេញដីកាការពារជាថ្មី ស្របតាមស្ថានភាពជាក់ស្តែង ឬបទបញ្ជាណាមួយក្នុងលក្ខណៈសមស្រប ។

### ២.៣.២. ប្រភេទ

ដីកាការពារមានពីរដំណាក់កាល ÷

- **ដំណាក់កាលទី១** ហៅថា ដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល**២ខែ** ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ ។
- **ដំណាក់កាលទី២** ហៅថា ដីកាការពារមានរយៈពេល**៦ខែ** ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬមុនពេលចេញសាលក្រមស្ថាពរ ។

### ២.៣.៣. ផលប្រយោជន៍

តុលាការអាចចេញដីកាការពារបណ្តោះអាសន្ននៅពេលទទួលបណ្តឹងការពារ ដោយមិនចាំបាច់សាកសួរជនមុខសញ្ញា បើសិនវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ ។

ក្នុងការចេញដីកាការពារ តុលាការមានសិទ្ធិកំណត់បញ្ជាលើសកម្មភាពជនមុខសញ្ញា ដើម្បីការពារជនរងគ្រោះ ដូចតទៅ ÷

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង
- ហាមចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច ។
- ហាមជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះតាមផ្លូវណាមួយ

- ហាមបំផ្លាញទ្រព្យ ឬចាត់ចែងលក់ទ្រព្យរបស់ជនរងគ្រោះ ឬញាតិសាលោហិតរបស់ជនរងគ្រោះ
- បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬបំបែកជនរងគ្រោះ បើមានការស្នើសុំ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។

បើយល់ថាជាការចាំបាច់សម្រាប់ការពារ ឬរៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ដោយចាត់វិធានការបន្ថែមទៀត ដូចតទៅ ÷

- បញ្ជាឱ្យភ្នាក់ងារនគរបាល ឬកងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ
- សម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយគិតយ៉ាងខ្ពស់បំផុតអំពីសិទ្ធិ និងឧត្តមប្រយោជន៍នៃកុមារនោះ
- បញ្ចប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះ ចំពោះជនមុខសញ្ញា
- កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុឱ្យជនរងគ្រោះ ដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា។

## ២.៣.៤. អ្នកស្នើសុំ

ពាក្យបណ្តឹងសុំដីកាការពារពីតុលាការ អាចធ្វើឡើងដោយ ÷

- ជនរងគ្រោះ ឬតំណាងជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ។
- ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន។

**ដីកាការពារអាចស្នើសុំបាន នៅពេលស្នើសុំអន្តរាគមន៍ឬនៅពេលស្នើសុំសេចក្តីសម្រេចរដ្ឋបាល។**

## ២.៣.៥. ការប្តឹងតវ៉ា

គូភាគីអាចធ្វើការតវ៉ាឱ្យតុលាការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរ**២ខែ** ចាប់ពីថ្ងៃចេញដីកាការពារ។

បើមានសំណើពីភាគីណាមួយ តុលាការអាចកែប្រែ លុបចេញ ឬបន្ថែមទម្ងន់នៅក្នុងដីកាការពារ ក្រោយពីបានជូនដំណឹងទៅភាគីម្ខាងទៀត**៥ថ្ងៃ** មុននឹងសម្រេច។

## ២.៣.៦. សមត្ថកិច្ចចេញដីកាការពារ

មានតែតុលាការខេត្ត ក្រុងទេ ដែលមានសមត្ថកិច្ចចេញដីកាការពារ ជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នា ជាផ្នែកស៊ីវិលក្តី ជាផ្នែករដ្ឋបាលក្តី ឬជាផ្នែកព្រហ្មទណ្ឌក្តី។

# ផ្នែកទី៣

# ការជួយ និងជំនួយ

# ផ្នែកទី៣
# ការជួយ និងជំនួយ

## ៣.១. វិធីដែលមិនជួយ

វិធីដែលមិនជួយ គឺជាការបង្ហាញឱ្យឃើញនូវឥរិយាបថប្រព្រឹត្តមិនគប្បីមួយចំនួនរបស់មនុស្សទាំងឡាយ ឬអ្នកផ្តល់សេវា ដែលបានស្តែងចេញទៅលើជនរងគ្រោះ ក្នុងខណៈដែលជនរងគ្រោះកំពុងស្វែងរកសេវាជំនួយ។ ឥរិយាបថនេះ អាចបង្កើនអំណាច និងការត្រួតត្រាតាមបែបហិង្សាដល់ជនមុខសញ្ញា និង**បង្កគ្រោះថ្នាក់កាន់តែខ្លាំងឡើងដល់ជនរងគ្រោះ**។

### សេចក្តីពន្យល់
### អំពីរបៀបមើលកង់ចក្រវិធីដែលមិនជួយ នាំឱ្យគ្រោះថ្នាក់កាន់តែខ្លាំងឡើង

កង់ចក្រនេះ មានរាងជារង្វង់ ដែលមាន៣ជាន់ គឺ ÷

☞ **រង្វង់ទី១** (រង្វង់ខាងក្រៅ) មានអក្សរធំៗនៅខាងលើ និងខាងក្រោម សរសេរថា **គ្រោះថ្នាក់កាន់តែខ្លាំងឡើង**។ ផ្នែករង្វង់ខាងក្រៅនេះ ជាទិដ្ឋភាពរួមនៃគ្រោះថ្នាក់ដែលនឹងកើតមានទៅលើជនរងគ្រោះ នៅពេលដែលសកម្មភាពហិង្សាបានកើតឡើងនៅក្នុងគ្រួសារ ហើយជនរងគ្រោះបានទៅរកសេវាជំនួយ ប៉ុន្តែអ្នកផ្តល់សេវាបែរជាមានអាកប្បកិរិយាមិនគប្បីដាក់ជនរងគ្រោះទៅវិញ។

☞ **រង្វង់ទី២** ចែកចេញជា៦ចំណែក រាងដូចកាំរទេះ ហើយចំណែកទាំង៦នោះ មានលើកឡើងនូវឥរិយាបថមិនគប្បីខ្លះ ដែលយើងទាំងអស់គ្នា ជាពិសេសអ្នកផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ មិនត្រូវអនុវត្ត ÷

- រំលោភលើការរក្សាការសម្ងាត់
- ចាត់ទុករឿងរំលោភបំពាន ថាជារឿងកំប៉ិកកំប៉ុកតូចតាច
- ស្តីបន្ទោសជនរងគ្រោះ
- មិនគោរពស្វ័យភាពរបស់ជនរងគ្រោះ
- ព្រងើយកន្តើយនឹងសេចក្តីត្រូវការសុវត្ថិភាពរបស់ជនរងគ្រោះ
- ចាត់ទុកជនរងគ្រោះ ជារឿងធម្មតា។

☞ **រង្វង់ខាងក្នុង ឬស្នូល** មានអក្សរថា **អំណាច និងការត្រួតត្រា** គឺនិយាយអំពីអំណាច និងការត្រួតត្រាតាមបែបហិង្សារបស់ជនមុខសញ្ញាប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។

☞ **អត្ថន័យ :**

ប្រសិនបើសកម្មភាពដូចមានក្នុងរង្វង់ទី២ ត្រូវបានអនុវត្ត នោះរង្វង់ខាងក្នុងដែលជាស្នូល ក៏កាន់តែរីកធំឡើងៗ ហើយរង្វង់ទី១ (រង្វង់ខាងក្រៅ) ក៏កាន់តែរីកធំថែមទៀតដែរ។ មានន័យថា ប្រសិនបើជនទាំង

ឡាយ ជាពិសេសអ្នកផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សា បានអនុវត្តនូវឥរិយាបថមិនសមរម្យចំពោះជនរងគ្រោះ ធ្វើឱ្យជនរងគ្រោះមានអារម្មណ៍អស់សង្ឃឹម លែងព្យាយាមស្វែងរកដំណោះស្រាយ ឬអាចយល់ថា ខ្លួនគឺជាអ្នកមានកំហុសនៅក្នុងរឿងនេះ ហើយសុខចិត្តស៊ូទ្រាំរស់នៅក្នុងគ្រួសារមួយ ដែលពោរពេញដោយអំពើហិង្សា និងគ្មានសេរីភាព។ ចំណែកជនមុខសញ្ញាវិញ នឹងមានអំណាច និងការត្រួតត្រាតាមបែបហិង្សាកាន់តែខ្លាំងឡើងៗ។ ទីបំផុត គ្រោះថ្នាក់ដែលបង្កឡើងដោយជនមុខសញ្ញា វានឹងរីករាលដាលកាន់តែធំទៅៗធ្លាក់ទៅលើជនរងគ្រោះ និងជាវិបត្តិរបស់សង្គមជាតិទាំងមូលផងដែរ។

### កង់ចក្រអំពើវិធីដែលមិនជួយ នាំឱ្យគ្រោះថ្នាក់កាន់តែខ្លាំងឡើង



## ៣.២. វិធីដែលជួយ

វិធីដែលជួយ ឬការជួយដែលមានប្រសិទ្ធភាព គឺជាការបង្ហាញនូវឥរិយាបថឆ្លើយតបដ៏ល្អរបស់មនុស្សទាំងឡាយ ជាពិសេស ឥរិយាបថរបស់អ្នកផ្តល់សេវាជំនួយ ចំពោះជនរងគ្រោះដោយសារអំពើហិង្សា។ ឥរិយាបថនេះអាចជួយផ្តល់អំណាច និងការតស៊ូមតិដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ដើម្បីចាកផុតពីការគាបសង្កត់ និងទទួលបានសិទ្ធិសេរីភាពពេញលេញ។

### សេចក្តីពន្យល់
### អំពីរបៀបមើលកង់ចក្រវិធីដែលជួយ នាំឱ្យការជួយមានប្រសិទ្ធភាព

កង់ចក្រនេះ មានរាងជារង្វង់ ដែលមាន៣ជាន់ ÷

☞ **រង្វង់ទី១** (រង្វង់ខាងក្រៅ) មានអក្សរនៅព័ទ្ធជុំវិញ គឺ ÷

- **ខាងលើ និងខាងក្រោម** មានអក្សរធំៗថា **ការជួយមានប្រសិទ្ធភាព**
- **ខាងឆ្វេង និងខាងស្តាំ** មានអក្សរតូចៗ ដូចជា កសាងសុវត្ថិភាព តម្លៃចំពោះខ្លួន ទំនុកចិត្ត ដើម្បីធ្វើការសម្រេចចិត្ត។

ផ្នែករង្វង់ខាងក្រៅនេះ ជាទិដ្ឋភាពរួមនៃការជួយជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ តាមមធ្យោបាយប្រកបដោយប្រសិទ្ធភាព។

☞ **រង្វង់ទី២** ចែកចេញជា៦ចំណែក រាងដូចកាំរទេះ ហើយចំណែកទាំង៦នោះ មានលើកឡើងនូវឥរិយាបថល្អៗដែលយើងទាំងអស់គ្នា ជាពិសេសអ្នកផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ត្រូវអនុវត្ត ÷

- គោរព និងរក្សាការសម្ងាត់
- ជឿ និងឱ្យតម្លៃទៅលើបទពិសោធន៍របស់ជនរងគ្រោះ
- ទទួលស្គាល់ភាពអយុត្តិធម៌ចំពោះជនរងគ្រោះ
- គោរពស្វ័យភាពរបស់ជនរងគ្រោះ
- ជួយដើម្បីធ្វើផែនការសុវត្ថិភាពទៅអនាគត
- ផ្តល់សេវាកម្ម។

☞ **រង្វង់ខាងក្នុង ឬស្នូល** មានអក្សរថា **ផ្តល់អំណាច ការតស៊ូមតិ។**

- ការផ្តល់អំណាច គឺជាការផ្តល់ឱកាសឱ្យជនរងគ្រោះ រកជម្រើសក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង មិនមែនបង្ខំឱ្យជនរងគ្រោះត្រូវតែធ្វើតាមយោបល់របស់ជនមុខសញ្ញា ឬអ្នកផ្តល់សេវាជំនួយនោះឡើយ។
- ការតស៊ូមតិ គឺជាការផ្តល់ឱកាសឱ្យជនរងគ្រោះបញ្ចេញមតិយោបល់ លាតត្រដាងពីការពិត រៀបរាប់ពីទុក្ខកង្វល់ដែលគាត់មាន វិធានការសុវត្ថិភាពដែលគាត់គួរជ្រើសរើសដើម្បីធ្វើការសម្រេចចិត្ត និងចម្ងល់ផ្សេងៗរបស់គាត់ ...។

☞ **អត្ថន័យ :**

បើសកម្មភាពដូចមានក្នុងរង្វង់ទី២ត្រូវបានអនុវត្ត នោះរង្វង់ខាងក្នុងដែលជាស្នូល ក៏កាន់តែរីកធំឡើងៗ ហើយរង្វង់ទី១ (រង្វង់ខាងក្រៅ) ក៏កាន់តែរីកធំថែមទៀតដែរ។ មានន័យថា បើជនទាំងឡាយ ជាពិសេសអ្នកផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ បានប្រតិបត្តិនូវឥរិយាបថល្អៗ ចំពោះជនរងគ្រោះ នឹងធ្វើឱ្យជនរងគ្រោះមានឱកាស មានទំនុកចិត្ត មានក្តីសង្ឃឹម និងមានអារម្មណ៍ជឿជាក់លើខ្លួនឯង គិតថាខ្លួនជាមនុស្សមានតម្លៃ និងព្យាយាមស្វែងរកដំណោះស្រាយសមស្របសម្រាប់ខ្លួនផ្ទាល់។

**កង់ចក្រអំពីវិធីដែលជួយ នាំឱ្យការជួយមានប្រសិទ្ធភាព**



## ៣.៣. ឧបសគ្គនៅក្នុងការផ្លាស់ប្តូរទំនាក់ទំនងដែលមានការរំលោភបំពាន

មនុស្សគ្រប់រូប សុទ្ធតែមានបំណងដូចៗគ្នាក្នុងការរស់នៅក្នុងសង្គមគ្រួសារមួយដែលមានសុខសន្តិភាព សុវត្ថិភាព និងសុភមង្គលភ្លឺស្វាង។ ចុះហេតុអ្វីបានជាមានជនរងគ្រោះមួយចំនួន ស៊ូទ្រាំបន្តរស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា? តើហេតុអ្វីបានជាមានការលំបាកនៅក្នុងការផ្លាស់ប្តូរស្ថានការណ៍? ។

ខាងក្រោមនេះ គឺគ្រាន់តែជាមូលហេតុមួយចំនួនតូច ក្នុងចំណោមមូលហេតុផ្សេងៗជាច្រើន ដែលជនរងគ្រោះ មានការលំបាកនៅក្នុងការផ្លាស់ប្តូរស្ថានការណ៍ ÷

### ៣.៣.១. ជនរងគ្រោះខ្លាចមានការរើសអើង

ជនរងគ្រោះតែងតែមានអារម្មណ៍គិតដល់បញ្ហាអាពាហ៍ពិពាហ៍ ឋានៈគ្រួសារក៏ដូចជានៅក្នុងសង្គម (ឧទាហរណ៍ ជាស្ត្រីមេម៉ាយ ជាប្រពន្ធចុង ជាប្តីចុង ជាម្តាយចុង ជាកូនចុង ជាកូនដើម ជាកូនកំព្រា ...។ល។) និងភាពស្មោះត្រង់ចំពោះគ្រួសារ។ លើសពីនេះទៀត ជនរងគ្រោះអាចទទួលឥទ្ធិពលគាបសង្កត់ពីក្រុមគ្រួសារ ឬសហគមន៍របស់ខ្លួន។

### ៣.៣.២. ជនរងគ្រោះភ័យខ្លាចអំពីសុវត្ថិភាពសមាជិកគ្រួសារ

ជនមុខសញ្ញាមួយចំនួន បានគំរាមកំហែងដល់ជនរងគ្រោះថា ប្រសិនបើជនរងគ្រោះចាកចេញ ឬរាយការណ៍ទៅសមត្ថកិច្ច ឬធ្វើឱ្យបែកការ ខ្លួននឹងឱ្យគេតាមធ្វើបាបដល់ជនរងគ្រោះ ឬខ្លួននឹងធ្វើបាបដល់សមាជិកដទៃទៀតក្នុងគ្រួសារ ដូចជា កូន ប្អូន ឬម្តាយ ...។ល។ ម្យ៉ាងទៀតជនរងគ្រោះមានជំនឿថា ខ្លួននឹងមិនមានលទ្ធភាពការពារខ្លួន ឬផ្តល់ការគាំទ្រដល់សមាជិកដទៃទៀតក្នុងគ្រួសារឡើយ។

### ៣.៣.៣. ជនរងគ្រោះព្រួយបារម្ភអំពីជីវភាពរស់នៅ

នៅក្នុងប្រទេសកម្ពុជា គ្រួសារមួយចំនួនបានពឹងផ្អែកអ្នករកចំណូលតែម្នាក់ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។ គ្រួសារខ្លះ ជនរងគ្រោះពឹងផ្អែកទាំងស្រុងទៅលើការរកចំណូលរបស់ជនមុខសញ្ញាដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។ គ្រួសារខ្លះ ជនមុខសញ្ញាមិនអនុញ្ញាត ឬមិនផ្តល់ឱកាសឱ្យជនរងគ្រោះរួមចំណែករកប្រាក់ចំណូលទេ។

ដូច្នេះជនរងគ្រោះ ព្រួយបារម្ភយ៉ាងខ្លាំងអំពីជីវភាពរស់នៅរបស់គ្រួសារ ប្រសិនបើពួកគេបែកបាក់គ្នា។

### ៣.៣.៤. ជនរងគ្រោះអាចមានជំនឿថា ខ្លួនគ្មានទីកន្លែងណាដែលត្រូវទៅនោះទេ

- ជនមុខសញ្ញា ដាក់ជនរងគ្រោះឱ្យនៅឯកោពីអ្នកដទៃ ហើយត្រួតត្រារាល់ការធ្វើទំនាក់ទំនងទាំងអស់របស់ជនរងគ្រោះ។
- ជនរងគ្រោះមិនមានមិត្តភក្តិណាដែលជនមុខសញ្ញា មិនស្គាល់នោះឡើយ។
- ក្រុមគ្រួសាររបស់ជនរងគ្រោះ អាចមិនផ្តល់ការគាំទ្រដល់គាត់ ឬពួកគេរស់នៅឆ្ងាយពីគាត់ពេក។
- ជនរងគ្រោះអាចមិនមានបងប្អូនក្រុមគ្រួសារ។
- មិត្តភក្តិរបស់ជនរងគ្រោះនោះ អាចមានការភ័យខ្លាច ឬត្រូវបានទទួលការគំរាមកំហែងពីជនមុខសញ្ញា។

- ជនរងគ្រោះភាគច្រើនមិនដឹងទៅរកទីភ្នាក់ងារណាមួយដែលអាចជួយខ្លួនបាន ឬមានការភ័យខ្លាចថា ការទាក់ទងជាមួយនឹងទីភ្នាក់ងារណាមួយ នឹងធ្វើឱ្យជនមុខសញ្ញាខឹងកាន់តែខ្លាំងថែមទៀត។
- សេវា និងទីជម្រកសុវត្ថិភាពមានតិចតួចបំផុតសម្រាប់ជនរងគ្រោះ។

## ៣.៣.៥. ជនរងគ្រោះនៅតែស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះជនមុខសញ្ញា

ទោះបីជាប្រឈមមុខចំពោះអ្វីៗក៏ដោយ ក៏ជនរងគ្រោះនៅតែស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះជនមុខសញ្ញាដដែល ដោយសារជនរងគ្រោះ ÷

- គិតថាជនមុខសញ្ញាជាមនុស្សល្អម្នាក់ ហើយរាល់កំហុសឆ្គងដែលជនមុខសញ្ញាបានប្រព្រឹត្តមកលើគ្រួសារ គឺព្រោះតែការស្រឡាញ់ប៉ុណ្ណោះ។
- គិតថាជនមុខសញ្ញាស្រវឹងស្រា ឬមានការតានតឹងចិត្តពីមជ្ឈដ្ឋានខាងក្រៅ ឬក៏ដោយសារខ្លួនឯងតែម្តងដែលមានកំហុស ទើបបានជាមានការរំលោភបំពាននោះ។
- គិតថាជនមុខសញ្ញាមានជំងឺ ឬស្ថិតនៅក្នុងវិបត្តិអ្វីមួយ ហើយត្រូវការឱ្យមានការយកចិត្តទុកដាក់។
- នៅនឹកឃើញអនុស្សាវរីយ៍ផ្អែមល្ហែមកាលពីពេលមុន ហើយនៅតែមានសង្ឃឹមថា ពេលវេលាដ៏មានសុភមង្គលនោះនឹងវិលត្រឡប់មកវិញ។

## ៣.៣.៦. ជនរងគ្រោះយល់ថាអំពើហិង្សា គឺជារឿងធម្មតា

ជនរងគ្រោះ អាចជាមនុស្សដែលបានរស់នៅ និងធំដឹងក្តីនៅក្នុងគ្រួសារមួយដែលមានអំពើហិង្សា ឬអាចធ្លាប់បានទទួលរងការរំលោភបំពាន ឬការធ្វើបាបកាលពីនៅជាកុមារ ឬត្រូវបានចិញ្ចឹមបីបាច់មកក្នុងបរិយាកាសមួយដែលមានអំពើហិង្សា។ ជនរងគ្រោះអាចមិនដែលឃើញគំរូណាមួយអំពីការរស់នៅក្នុងទំនាក់ទំនងគ្រួសារដែលមានសុភមង្គលឡើយ។

ហេតុដូច្នេះហើយ ទើបជនរងគ្រោះអាចមានជំនឿថា អំពើហិង្សា ឬការវាយដំ គឺជារឿងធម្មតាដែលអាចទទួលយកបាន។

## ៣.៣.៧. ជនរងគ្រោះមានជំនឿថា មិនអាចផ្លាស់ប្តូរស្ថានភាពបានទេ

ជនរងគ្រោះអាចយល់ថា គ្មាននរណាយកចិត្តទុកដាក់ចំពោះការរំលោភបំពានលើខ្លួន និងអាចយល់ថាខ្លួនជាមនុស្សមិនបានការ អសមត្ថភាព និងជាមនុស្សមិនមានការចាប់អារម្មណ៍ ឬការទាក់ទាញ ហើយគ្មាននរណាមួយអាចនឹងស្រឡាញ់ ឬទទួលខ្លួននោះឡើយ។ លើសពីនេះទៀត ជនរងគ្រោះអាចមានជំនឿថា ខ្លួនបានធ្វើអ្វីមួយខុសដែលបង្កឱ្យមានការរំលោភបំពាននោះ ឬវាគឺជាការសមហេតុសមផលអីចឹងមែន និងសមតែទទួលកម្មដូច្នេះ។

ការយល់បែបនេះធ្វើឱ្យជនរងគ្រោះធ្លាក់ទឹកចិត្ត និងមានការលំបាកក្នុងការប្រមូលអារម្មណ៍របស់ខ្លួនដើម្បីស្វែងរកជំនួយ និងប្រឈមជាមួយនឹងគ្រោះថ្នាក់នានា។

ដោយសារឧបសគ្គ និងជំនឿទាំងអស់នេះហើយ ដែលនាំឱ្យជនរងគ្រោះបន្តរស់នៅក្នុងទំនាក់ទំនង ដែលមានអំពើហិង្សានៅក្នុងគ្រួសារ។ **ការពិតជនរងគ្រោះចង់ឱ្យអំពើរំលោភបំពាននោះបញ្ចប់ មិនមែនពួកគេចង់បញ្ចប់ទំនាក់ទំនងគ្នាក្នុងគ្រួសារនោះទេ។**

## ៣.៤. ការពិគ្រោះយោបល់អំពីសុវត្ថិភាពជនរងគ្រោះ

នៅពេលពិគ្រោះយោបល់ជាមួយជនរងគ្រោះ ដើម្បីការពារសុវត្ថិភាពជនរងគ្រោះ អ្នកពិគ្រោះយោបល់គួរប្រើសំណួរមួយចំនួនដូចខាងក្រោម÷

- តើលោក លោកស្រីមានបញ្ហាអ្វីដែរ ?
- តើលោក លោកស្រី ត្រូវការអ្វីដើម្បីឱ្យមានសុវត្ថិភាព ?
- តើលោក លោកស្រី បានព្យាយាមប្រើមធ្យោបាយអ្វីខ្លះកន្លងមក ដើម្បីការពារខ្លួន កូន ឬសមាជិកគ្រួសារ ?
- តើមធ្យោបាយអ្វីខ្លះ ដែលអនុវត្តមានប្រសិទ្ធភាព និងមិនមានប្រសិទ្ធភាព?
- តើមានមធ្យោបាយណាដែលល្អបំផុត ដើម្បីធានាសុវត្ថិភាពនៅក្នុងពេលមានបញ្ហា?
- តើនរណាខ្លះដែលអ្នកទុកចិត្តដើម្បីទៅជួប និងស្នើសុំជំនួយឬការគាំទ្រ? (ឧទាហរណ៍ : មិត្តភក្តិ ឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន មន្ត្រីនគរបាល មន្ត្រីកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាល)
- តើនរណាខ្លះដែលអ្នកមិនទុកចិត្ត ? (ឧទាហរណ៍ : ក្រុមគ្រួសារ ឬមិត្តភក្តិជនមុខសញ្ញា ...។ល។)
- តើមានមធ្យោបាយក្នុងការផ្តល់សញ្ញាដើម្បីរកជំនួយដែរឬទេ? (ឧទាហរណ៍ ទូរស័ព្ទ វិទ្យុទាក់ទង ឱ្យសញ្ញាទៅកូនដើម្បីទៅប្រាប់អ្នកជិតខាង ... )

☞ **អនុសាសន៍មួយចំនួន ដើម្បីការពារសុវត្ថិភាពជនរងគ្រោះ :**

- ព្យាយាមផ្តល់សញ្ញាដល់អ្នកជិតខាង ដើម្បីជួយសង្គ្រោះនៅពេលមានអាសន្ន។
- ធ្វើការទាក់ទងជាមួយទីកន្លែងសុវត្ថិភាពទុកជាមុន ( វត្តអារាម ផ្ទះមិត្តភក្តិ ឬសាច់ញាតិ សាលាឃុំ ប៉ុស្តិ៍នគរបាល ...។ល។)
- ប្រសិនបើមានអាវុធនៅក្នុងផ្ទះ ត្រូវរកមធ្យោបាយយកអាវុធនោះចេញតាមដែលអាចធ្វើទៅបាន។

☞ **ជាអនុសាសន៍ ជនរងគ្រោះគួរយកសម្ភារមួយចំនួនដូចជា :**

- សម្លៀកបំពាក់។
- លុយកាក់មួយចំនួន។
- កូនសោបម្រុងមួយដែលអាចយកទៅចាក់ចេញចូលផ្ទះនោះបាន។

- រាល់ឯកសារជាផ្លូវការទាំងអស់ដែលទាក់ទងជាមួយនឹងខ្លួន និងកូន ដូចជា : អត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ឬឯកសារកម្មសិទ្ធិដីធ្លី និងផ្ទះដែលនៅក្នុងនោះមានឈ្មោះខ្លួនជាសហកម្មសិទ្ធិផងដែរ ។
- . . . ។ល ។

នៅក្នុងស្ថានការណ៍មួយដែលមានគ្រោះថ្នាក់ បញ្ហាសំខាន់ជនរងគ្រោះត្រូវតែជឿទុកចិត្តលើការសម្រេចចិត្តរបស់ខ្លួនផ្ទាល់ អំពីអ្វីដែលល្អបំផុត និងអ្វីដែលអាចដំណើរការទៅបាន ដើម្បីការពារខ្លួន និងសមាជិកគ្រួសារ ។ ជួនកាលការរត់គេចខ្លួនអាចជាការល្អបំផុត ឬការព្យាយាមរម្ងាប់កំហឹងរបស់ជនមុខសញ្ញារួចទើបធ្វើការរត់គេចខ្លួននៅពេលក្រោយក៏អាចជាមធ្យោបាយដ៏ល្អដែរ ។

## ៣.៥. សកម្មភាពសហគមន៍

### ☞ គំនិតផ្សេងៗសម្រាប់សកម្មភាពនៅក្នុងសហគមន៍

- រៀបចំ និងធ្វើការអប់រំ ផ្សព្វផ្សាយ អំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍របស់ខ្លួន ។
- ផ្សព្វផ្សាយប័ណ្ណ ឬកូនសៀវភៅស្តីពីអំពើហិង្សាក្នុងគ្រួសារ នៅតាមទីកន្លែងឯកជននានា ។
- ប្រសិនបើលោក លោកស្រី បានដឹងអំពីអំពើហិង្សាក្នុងគ្រួសារដែលកើតឡើងនៅក្នុងសហគមន៍របស់ខ្លួន ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយធ្វើអន្តរាគមន៍ ។
- បង្ហាញអាកប្បកិរិយាឱ្យជនមុខសញ្ញាដឹងថា យើងមិនគាំទ្រដល់សកម្មភាពហិង្សាណាមួយទេ ។
- ត្រូវមានឆន្ទៈស្តាប់ជនរងគ្រោះ ហើយព្យាយាមជួយជនរងគ្រោះ ។
- ផ្តល់ទីជម្រកបណ្តោះអាសន្ន ឬមធ្យោបាយធ្វើដំណើរ នៅពេលដែលមានសេចក្តីត្រូវការ ។
- ប្រៀនប្រដៅកូនចៅឱ្យមានភាពអហិង្សា ។
- លើកទឹកចិត្តសាលារៀននានា ឱ្យជជែកគ្នាអំពីអំពើហិង្សាក្នុងគ្រួសារនៅក្នុងថ្នាក់រៀន ។
- ប្រឈមមុខជំទាស់ជាមួយនឹងអាកប្បកិរិយា និងពាក្យសំដីដែលលើកទឹកចិត្តឱ្យមានអំពើហិង្សា រាប់ទាំងការរើសអើងជាតិសាសន៍ បញ្ហាផ្លូវភេទ និងអំពើអនាចារ ។
- ស្នើសុំគ្រូពេទ្យឱ្យជជែកអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ ជាមួយនឹងអ្នកជំងឺ ។
- រៀបចំទីជម្រកបណ្តោះអាសន្ននៅក្នុងសហគមន៍សម្រាប់ជនរងគ្រោះ ។
- ធ្វើសកម្មភាពផ្សេងៗទៀតដែលមានប្រយោជន៍ដល់ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ។

### ☞ កង់ចក្រសេចក្តីប្រាថ្នានៅក្នុងការធ្វើឱ្យមានភាពខុសប្លែកគ្នា

កង់ចក្រសេចក្តីប្រាថ្នានៅក្នុងការធ្វើឱ្យមានភាពខុសប្លែកគ្នានេះ គឺជាការផ្លាស់ប្តូរមួយទៅលើកង់ចក្រផ្សេងៗទៀត ដែលបានណែនាំនៅក្នុងឯកសារបណ្តុះបណ្តាលនេះ ។ កង់ចក្រនេះ បង្ហាញអំពីរបៀបផ្សេងៗ នៅក្នុងទម្រង់ខ្លីៗ ដែលសហគមន៍អាចធ្វើសកម្មភាព ដើម្បីគាំទ្រដល់ជនរងគ្រោះដោយសារអំពើហិង្សា ហើយឱ្យជនមុខសញ្ញាទទួលខុសត្រូវចំពោះអាកប្បកិរិយារបស់ខ្លួន ។

## សេចក្តីពន្យល់

## អំពីរបៀបមើលគំនូសចក្រសេចក្តីប្រាថ្នា នៅក្នុងការធ្វើឱ្យមានភាពខុសប្លែកគ្នា

កង់ចក្រនេះ មានរាងជារង្វង់ ដែលមាន៣ជាន់ គឺ ÷

☞ **រង្វង់ទី១** (រង្វង់ខាងក្រៅ) មានអក្សរធំ៧ថា **សេចក្តីប្រាថ្នានៅក្នុងការធ្វើឱ្យមានភាពខុសប្លែកគ្នា។** ផ្នែករង្វង់ខាងក្រៅនេះ ជាទិដ្ឋភាពរួមនៃសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូប នៅក្នុងសហគមន៍ ដែលចង់ឱ្យសហគមន៍របស់ខ្លួនប្រែមុខមាត់ថ្មី។

☞ **រង្វង់ទី២** ចែកចេញជា៦ចំណែក រាងដូចកាំរទេះ ហើយចំណែកទាំង៦នោះ មានលើកឡើងនូវសកម្មភាពនៃការជួយជំរុញឱ្យសេចក្តីប្រាថ្នារបស់សហគមន៍ទាំងមូល អាចសម្រេចបាន :

- អ្នកផ្តល់សេវាសង្គមកិច្ច
- ប្រព័ន្ធថែរក្សាសុខភាព
- ប្រព័ន្ធអប់រំ
- អ្នកជិតខាង សាច់ញាតិ និងមិត្តភក្តិ
- អាជ្ញាធរមូលដ្ឋាន
- សារព័ត៌មាន

☞ **រង្វង់ខាងក្នុង ឬស្នូល** មានអក្សរថា **សហគមន៍។**

សហគមន៍ គឺសំដៅទៅលើក្រុមមនុស្សទាំងឡាយ ដែលមានបរិយាយនៅក្នុងកាំទាំង៦។ ប្រសិនបើ លោក លោកស្រី មិនអាចអនុវត្តទៅតាមគោលការណ៍ទាំងនេះបាន នោះសេចក្តីប្រាថ្នារបស់សហគមន៍ទាំងមូល នឹងមិនអាចសម្រេចគោលបំណងបានឡើយ។

## កង់ចក្រសេចក្តីក្លាហាន នៅក្នុងការធ្វើឱ្យមានភាពខុសប្លែកគ្នា



## ៣.៦. សេវាសម្របសម្រួលផ្តល់ជំនួយក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ

ភូមិ................. ឃុំ សង្កាត់ ................. ស្រុក ខណ្ឌ................. ខេត្ត ក្រុង.................

| ល.រ | ឈ្មោះមនុស្ស | តួនាទី ឬឈ្មោះស្ថាប័ន | ភារកិច្ច | អាសយដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | | អ្នកជិតខាង ឬចាស់ទុំដែលជាទីទុកចិត្ត | ជំនួយ និងការបញ្ជូន | | |
| ២ | | មេភូមិ | ជំនួយ ការបញ្ជូន និងការធ្វើអន្តរាគមន៍ | | |
| ៣ | | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ជំនួយ ការបញ្ជូន ការធ្វើអន្តរាគមន៍ និងជំនួយផ្នែកច្បាប់ | | |
| ៤ | | អ្នកទទួលបន្ទុកការងារស្ត្រី និងកុមារ | ជំនួយ និងការបញ្ជូន | | |
| ៥ | | ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ | ជំនួយការបញ្ជូន ការធ្វើអន្តរាគមន៍ និងការស៊ើបអង្កេត | | |
| ៦ | | អធិការដ្ឋាននគរបាលស្រុក ខណ្ឌ | ការធ្វើអន្តរាគមន៍ ការស៊ើបអង្កេត និងការបញ្ជូន | | |
| ៧ | | កងរាជអាវុធហត្ថ | ការធ្វើអន្តរាគមន៍ ការស៊ើបអង្កេត និងការបញ្ជូន | | |
| ៨ | | មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | ជំនួយជំហានដំបូង និងលិខិតកោសល្យវិច័យ | | |
| ៩ | | ការិយាល័យកិច្ចការនារី | ជំនួយ ការបញ្ជូន និងជំនួយផ្នែកច្បាប់ | | |
| ១០ | | ការិយាល័យសង្គមកិច្ច | ជំនួយ ការបញ្ជូន និងជំនួយផ្នែកច្បាប់ | | |
| ១១ | | អង្គការ .....(ឈ្មោះអង្គការ)........ | ទីជម្រក ការបញ្ជូន ជំនួយផ្នែកច្បាប់ និងផ្សេងៗទៀត | | |

- បើមានករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ត្រូវទំនាក់ទំនងទៅស្ថាប័ន ឬអ្នកផ្តល់សេវាសម្របសម្រួលដែលនៅជិតមផុត
- ឃុំ សង្កាត់ ត្រូវរៀបចំ **"បញ្ជីសេវាសម្របសម្រួលផ្តល់ជំនួយក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ"** ហើយធ្វើការបិទផ្សាយ និងចែកផ្សាយឱ្យបានទូលំទូលាយនៅក្នុងឃុំ សង្កាត់។
- **បញ្ជីសេវាសម្របសម្រួលផ្តល់ជំនួយក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ**ត្រូវធ្វើការកែសម្រួលនៅពេលមានការប្រែប្រួល។

## ៣.៧. ការត្រួតពិនិត្យតាមដានទៅលើករណីអំពើហិង្សានៅតាមសហគមន៍

### ៣.៧.១. សារៈសំខាន់នៃការត្រួតពិនិត្យតាមដានករណីអំពើហិង្សាក្នុងគ្រួសារ

- អាចមើលឃើញពីស្ថានភាពដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើង
- ងាយស្រួលក្នុងការវិភាគបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងរកឃើញនូវមូលហេតុទាំងឡាយ និងដំណោះស្រាយ
- យកព័ត៌មាននោះសម្រាប់ធ្វើជាឯកសារនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍សហគមន៍របស់ខ្លួន
- គ្រប់គ្រងទិន្នន័យបានល្អ ជាហេតុនាំឱ្យមានការដោះស្រាយបញ្ហាបានទាន់ពេលវេលា
- បង្ហាញអំពីភាពជាគំរូនៅក្នុងការគ្រប់គ្រងការងាររដ្ឋបាលភូមិ ឃុំ សង្កាត់
- ជាការសង្ខេបនូវព័ត៌មានរបាយការណ៍ខ្លីមួយយ៉ាងល្អ
- ងាយស្រួលសម្រាប់ការបូកសរុបព័ត៌មានអំពីអំពើហិង្សា សម្រាប់ធ្វើរបាយការណ៍អំពីអ្វីមួយដែលពាក់ព័ន្ធ
- អាចផ្តល់ជាប្រភពព័ត៌មាននៅក្នុងការស្រាវជ្រាវ និងការកែលំអសកម្មភាពអភិវឌ្ឍន៍នៅក្នុងសហគមន៍
- ផ្តល់ជាមេរៀននៅក្នុងការកែសម្រួលប្រព័ន្ធត្រួតពិនិត្យតាមដាន នៅតាមសហគមន៍របស់ខ្លួនឯងផ្ទាល់
- បង្កើតបាននូវបណ្តាញមួយនៅក្នុងការត្រួតពិនិត្យតាមដានអំពីស្ថានភាពនៃអំពើហិង្សានៅក្នុងសហគមន៍។

## ៣.៧.២. តារាងព័ត៌មានស្តីពីអំពើហិង្សាក្នុងគ្រួសារនៅតាមសហគមន៍ ប្រចាំខែ...... ឆ្នាំ........

ភូមិ................ ឃុំ សង្កាត់................ ស្រុក ខណ្ឌ................ខេត្ត ក្រុង................

| លេខរៀង | កាលបរិច្ឆេទកើតហេតុ | ទីកន្លែងកើតហេតុ | អំពើហិង្សា | | ស្ថានភាពទំនាក់ទំនង | |
|---|---|---|---|---|---|---|
| | | | ប្រភេទ | ការប្រព្រឹត្តហិង្សាដោយប្រើ | ជនរងគ្រោះ | ជនមុខសញ្ញា |
| | កត់ត្រា ថ្ងៃខែឆ្នាំ កើតហេតុ | កត់ត្រាទីកន្លែង ( លេខផ្ទះ លេខផ្លូវ ភូមិ ឃុំ សង្កាត់) កើតហេតុ | ១. អំពើហិង្សាផ្លូវកាយ<br>២. អំពើហិង្សាផ្លូវភេទ<br>៣. អំពើហិង្សាផ្លូវចិត្ត<br>៤. អំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច | កត់ត្រាប្រភេទឧបករណ៍ដែលប្រើប្រាស់ពេលមានជម្លោះ ដូចជា :<br>• កាំបិត<br>• ដំបង<br>• ដៃ<br>• ជើង<br>• . . . ។ល។ | ជនរងគ្រោះ ត្រូវជាអ្វីនឹង ជនមុខសញ្ញា | ជនមុខសញ្ញា ត្រូវជាអ្វីនឹង ជនរងគ្រោះ |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃទី........ ខែ............ ឆ្នាំ.........

**មេភូមិ**

## ៣.៧.៣. តារាងព័ត៌មានស្តីពីការធ្វើអន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសារ ប្រចាំខែ...... ឆ្នាំ........

ឃុំ សង្កាត់................ ស្រុក ខណ្ឌ................ ខេត្ត ក្រុង................

| លេខរៀង | កាលបរិច្ឆេទកើតហេតុ | ទីកន្លែងកើតហេតុ | ប្រភេទអំពើហិង្សា | ការធ្វើអន្តរាគមន៍ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | អន្តរាគមន៍ដោយ | វិធានការ | ចាប់ផ្តើម | បញ្ចប់ | |
| | ស្រង់ចេញពី កូឡោនទី២ នៃតារាងភូមិ | ស្រង់ចេញពី កូឡោនទី៣ នៃតារាងភូមិ | ស្រង់ចេញពី កូឡោនទី៤ នៃតារាងភូមិ | • មន្ត្រីកិច្ចការនារី<br>• ក្រុមប្រឹក្សាឃុំ<br>• នគរបាល | • ចេញសេចក្តីសម្រេចរដ្ឋបាល<br>• ការធ្វើអន្តរាគមន៍ជាបន្ទាន់<br>• សម្រុះសម្រួល<br>• ការអប់រំ | ថ្ងៃខែឆ្នាំ ចាប់ផ្តើម អន្តរាគមន៍ | ថ្ងៃខែឆ្នាំ បញ្ចប់ អន្តរាគមន៍ | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ថ្ងៃទី........ ខែ............ ឆ្នាំ.........

**មេឃុំ ចៅសង្កាត់**

ឧបត្ថម្ភដោយ

កិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ gtz

គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ (CCDP)